# ឧបករណ៍នាវិកវៃឆ្លាត



កម្រងសៀវភៅត្រួសត្រាយផ្លូវ



# សេចក្តីថ្លែងអំណរគុណ

លោក Camilla Jordanwood ជាអ្នកនិពន្ធសំខាន់ជាងគេបង្អស់នៃ ឧបករណ៍នាវិកវៃឆ្លាតនេះ បានបង្ហាញនូវការផ្ញើជូន និងការប្តេជ្ញាចិត្តដ៏ខ្លាំងក្លាក្នុងការបង្កើតនូវឯកសារបង្ហាញផ្លូវសម្រាប់ បំណិនជីវិតនេះឡើង ដែលបង្រៀនយុវវ័យអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និង ហានិភ័យនៃការជួញដូរមនុស្ស។

ឧបករណ៍នាវិកវៃឆ្លាតនេះ ត្រូវពិនិត្យឡើងវិញ និងកែសម្រួលដោយលោក John Whan Yoon ជាអ្នកគ្រប់គ្រងកម្មវិធីបញ្ឈប់ ការជួញដូរមនុស្សរបស់អង្គការទស្សនៈពិភពលោក, Amy Collins ជាអ្នកគ្រប់គ្រងគម្រោងបង្ការនៃកម្មវិធីបញ្ឈប់ការជួញដូរមនុស្ស (ETIP) របស់ អង្គការទស្សនៈពិភពលោក, Tiffany Tao Joiner, ជាអ្នកជំនាញផ្នែកការចូលរួមរបស់កុមារ និង សុខុមាលភាពកុមារ និងសិទ្ធិកុមាររបស់អង្គការ ទស្សនៈពិភពលោក, Aimyleen Gabriel ជា អ្នកគ្រប់គ្រងកម្មវិធីការពារកុមាររបស់ អង្គការទស្សនៈពិភពលោក និង Mandy Yamanis អ្នកមជ្ឈមណ្ឌលសិក្សាផ្នែកការការពារ និងការចូលរួមរបស់កុមារនៃ អង្គការទស្សនៈពិភពលោក

ខ្ញុំសូមថ្លែងអំណរគុណចំពោះបុគ្គលិកកម្មវិធី ETIP ទាំងអស់សម្រាប់ការជួយជ្រោមជ្រែង របស់ពួកគាត់ក្នុងការណែនាំដល់ការបង្កើត ឧបករណ៍នាវិកវៃឆ្លាតនេះ រួមទាំងភាព បង្កប់នូវអត្ថន័យនៃវប្បធម៌ផងដែរ។ បុគ្គលិកទាំងអស់រួមមាន ពេជ្រ គឹមធា និងជា សុផល នៃកម្មវិធី ETIP កម្ពុជា, Fei Wang និង Xue Lian Xie ETIP ប្រទេសចិន, Southasa Bousdy និង Phouthaluck Phontsaona នៃកម្មវិធី ETIP ប្រទេសឡាវ, Ban Aung និង Khin Myo Thant មកពីកម្មវិធី ETIP ប្រទេសមីយ៉ាន់ម៉ា។ Chinethai Rucsachart និង Natpimon Apipongpisarn នៃកម្មវិធី ETIP ប្រទេសថៃ និង Le Thi Thanh Hang និង Vu Thi Du នៃកម្មវិធី ETIP ប្រទេសវៀតណាម ។

ខ្ញុំសូមថ្លែងអំណរគុណជាអនេកប្បការផងដែរ ជូនចំពោះបណ្តាអ្នកជំនាញ អ្នកស្រាវជ្រាវ និងអ្នក តស៊ូមតិនានាដែលបានកំពុងសិក្សា និងបានផ្តល់ជាឯកសារអំពីការធ្វើចំណាកស្រុក ដោយ គ្មានសុវត្ថិភាព និងការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ ការងាររបស់ពួកគាត់គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការផ្តល់ព័ត៌មានអំពីការយល់ដឹង និងការស្វែងយល់អំពី ស្ថានភាពនៃការរំលោភបំពានទាំងនេះចំពោះសិទ្ធិកុមារ និងការការពារកុមារ។

ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅជូនចំពោះ អង្គការទស្សនៈពិភពលោក និង កម្មវិធី ETIP សម្រាប់ការធ្វើឲ្យគម្រោងមួយនេះកើតមានឡើង។
សូមអរគុណ
Amy Collins
អ្នកគ្រប់គ្រងគម្រោងបង្ការ និងទប់ស្កាត់ប្រចាំតំបន់នៃកម្មវិធី ETIP

# អារម្ភកថា

អំពើជួញដូរមនុស្សគឺជាឧក្រិដ្ឋកម្មដែលប៉ះពាល់ដល់បុរស ស្ត្រី និងកុមារនៅជុំវិញពិភពលោក។ អំពើនេះរួមមានការដាក់ ឬការឃុំឃាំងនរណាម្នាក់ឲ្យស្ថិតនៅក្នុងស្ថានភាពដែលមានការកេងប្រវ័ញ្ចមួយ ជាទូទៅគឺដើម្បី ផលចំណេញ។ ការកេងប្រវ័ញ្ចអាចរួមមាន ការបង្ខិតបង្ខំ ឬការធ្វើការងារដើម្បីដោះបំណុល ពលកម្មកុមារ ការកេងប្រវ័ញ្ចផ្លូវភេទ ខ្ញុំបម្រើតាមផ្ទះ ជម្លោះប្រដាប់អាវុធ។

មហាអនុតំបន់ទន្លេមេគង្គ(GMS)ត្រូវបានបង្កើតឡើងដោយប្រទេសចំនួន៦ដែលតភ្ជាប់គ្នាដោយទន្លេមេគង្គ រួមមាន ៖ប្រទេសកម្ពុជា ចិន សាធារណរដ្ឋប្រជាមានិតឡាវ មីយ៉ាន់ម៉ា ថៃ និងវៀតណាម។ ដោយសារ ឱកាសមានកម្រិតសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងស្របច្បាប់នៅក្នុងមហាអនុតំបន់ទន្លេមេគង្គនេះការធ្វើចំណាកស្រុកមិនទៀងទាត់គឺកើតមានគ្រប់កន្លែង ដោយបង្កើតឲ្យមាន ឱកាសប្រកប ដោយ សក្តានុពលសម្រាប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចមកលើជនចំណាកស្រុក។ ស្របពេលដែលទំហំនៃការជួញដូរមនុស្សមានការលំបាកក្នុងការបញ្ជាក់អះអាង ដោយសារតែស្ថានភាពខុសច្បាប់ និង ជាញឹកញាប់រកមិនឃើញនៃបទឧក្រិដ្ឋនេះ គឺមានភស្តុតាងជាច្រើនបង្ហាញថា មានទម្រង់នៃការជួញដូរមនុស្សដ៏អាក្រក់បំផុតនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ។ បណ្តារដ្ឋាភិបាលនៃប្រទេស GMS ទីភ្នាក់ងារនៃអង្គការសហប្រជាជាតិ និង អង្គការមិនមែនរដ្ឋាភិបាលជាច្រើន រួមទាំងអង្គការទស្សនៈពិភពលោកផងដែរ កំពុងធ្វើការងារយ៉ាងសស្រាក់សស្រាំដើម្បីប្រឆាំងនឹងការជួញដូរមនុស្សនេះ។ កម្មវិធីបញ្ចប់ការជួញដូរមនុស្ស (EITP) របស់អង្គការទស្សនៈពិភពលោក ដែលជាកម្មវិធីប្រឆាំងការជួញដូរមនុស្ស ថ្នាក់តំបន់មួយ កំពុងត្រូវបានអនុវត្តចាប់ពីខែតុលា ឆ្នាំ ២០១១ ដល់ ខែកញ្ញា ឆ្នាំ ២០១៦។ តាមរយៈការធ្វើការងារជាមួយនឹងប្រទេសទាំង៦ នៅក្នុង GMS កម្មវិធី EITP ពេលនេះគឺជាកម្មវិធីប្រឆាំងការជួញដូរមនុស្សដ៏ធំជាងគេបង្អស់ក្នុងចំណោម កម្មវិធីប្រភេទនេះ និងមានគម្រោងចំនួន ៣ ៖ ការទប់ស្កាត់ ការការពារ និងគោលនយោបាយ។ ដោយសារតែអង្គការទស្សនៈពិភពលោក យល់ឃើញថា កុមារ និងយុវជនមានសារៈសំខាន់ខ្លាំង ក្នុងការធ្វើឲ្យមានការផ្លាស់ប្តូរនេះ និងប្រកាន់ខ្ជាប់នូវសិទ្ធិកុមារ និង យុវជនដើម្បីចូលរួមផ្ទាល់នៅក្នុង សកម្មភាពប្រឆាំងនឹងការជួញដូរមនុស្សនោះ កម្មវិធី ETIP កំពុងចំណាយមូលនិធិ និងកំពុងផ្សារភ្ជាប់ ជាមួយនឹងសកម្មភាពរបស់យុវជន។ ទិដ្ឋភាពមួយនៃគម្រោងការបង្ការ និងទប់ស្កាត់គឺការ បង្កើតក្លិបសម្រាប់យុវជនដើម្បីឲ្យមានការជួបជុំគ្នាជាទៀងទាត់ ដើម្បីរៀនសូត្រចំណេះដឹង និងជំនាញនានាដើម្បីការពារខ្លួនគេពីការជួញដូរមនុស្ស និង ក៏ដើម្បីជួយចែករំលែកសារទៅកាន់មិត្តភ័ក្តិរបស់គេផងដែរ ។ ឯកសារបង្ហាញផ្លូវនេះត្រូវបានតាក់តែងឡើង ដើម្បីជួយដល់យុវជន ដែលងាយរងគ្រោះបំផុតឲ្យ អភិវឌ្ឍបំណិនជីវិតសំខាន់ៗ រួមមានជំនាញក្នុងការគិតស៊ីជម្រៅ ការធ្វើសេចក្តីសម្រេចចិត្ត ការទំនាក់ទំនង និងការចរចាប្រកបដោយប្រសិទ្ធភាព ការគ្រប់គ្រងខ្លួនឯង និងការរៀបចំផែនការគោលដៅជីវិត។ បំណិនជីវិតទាំងនេះនឹងជួយឲ្យយុវជនដឹងខ្លួនជានិច្ច និងជៀសផុតពីគ្រោះថ្នាក់ដែលអាចកើតមាននៅពេលគេជួបប្រទះ នឹងស្ថានភាពគ្រោះថ្នាក់ ដូចជានៅពេលដែលមានអ្នកជួញដូរមនុស្សព្យាយាមបោកបញ្ឆោតគេជាដើម។ យើងខ្ញុំជឿជាក់ថាឯកសារបង្ហាញផ្លូវនេះ មានប្រសិទ្ធភាព ក្នុងការរៀបចំជីវិត របស់យុវជន ដើម្បីឲ្យពួកគេអាចការពារខ្លួនគេ និងសហគមន៍របស់គេពីស្ថានភាពនៃការជួញដូរមនុស្សបាន។ ក្លឹបយុវជនត្រូវបានរៀបចំឡើងដើម្បីអនុវត្តនូវយុទ្ធសាស្ត្រទប់ស្កាត់ទាំងនេះប្រកបដោយនិរន្តរភាពរយៈពេលច្រើនឆ្នាំទៅមុខ និង នោះគឺជាជំហានទីមួយ។

Anges Ting

អ្នកដឹកនាំប្រចាំតំបន់ - អាស៊ីបូព៌ា

# ឧបករណ៍នាវិកវៃឆ្លាត





# មាតិកា


សេចក្តីថ្លែងអំណរគុណ ii

អារម្ភកថា. iii

សេចក្តីផ្តើម viii

**ផ្នែក"ក" ការរៀបចំបង្កើតក្លឹបយុវជននារីកវៃឆ្លាត**

ទម្រង់ស្តីពីការយល់ព្រម ៖ សម្រាប់ឪពុកម្តាយ ឬអ្នកថែទាំសមាជិកក្លឹបយុវជននារីកឆ្លាត ៣

ការប្រើប្រាស់ទម្រង់ត្រួតពិនិត្យខ្លួនឯងសម្រាប់អ្នកសម្របសម្រួល ៥

(ទម្រង់ស្វ័យតាមដាន)សម្រាប់អ្នកសម្របសម្រួល

ការប្រើប្រាស់ទំរង់ត្រួតពិនត្យខ្លួនឯង ៦

ការកសាងទំនាក់ទំនងក្រុម ៖ ល្បែងថាមពល ៩

ល្បែងពង្រឹងថ្នាក់ទី ២ ៖ ល្បែងបោះបាល់ប្រាប់ឈ្មោះ ១០

ល្បែងពង្រឹងថ្នាក់ទី ៣ ៖ អ្វីដែលអ្នកអាចនឹងមិនស្គាល់ ១១

ល្បែងពង្រឹងថ្នាក់ទី ៤ ៖ ល្បែងបាល់ចងចាំ ១២

ល្បែងពង្រឹងថ្នាក់ទី ៥ ៖ ល្បែងសួរសំណួរខ្លី ១៣

ល្បែងពង្រឹងថ្នាក់ទី ៦ ៖ ល្បែងលាក់កន្សែង ១៧

មេរៀនទី ១ ៖ ការណែនាំអំពីក្លិបរបស់យើង ១៨

មេរៀនទី ២ ៖ ការគិតអំពីជីវិតរបស់យើង ២៦

**ផ្នែក "ខ" ព័ត៌មានអំពីការជួញដូរមនុស្ស និង ការធ្វើចំណាកស្រុក** ២៩

មេរៀនទី ៣ ៖ តើអ្វីជាការជួញដូរមនុស្ស?តើអ្វីជាការចំណាកស្រុក? ៣១

មេរៀនទី ៤ ៖ ការជួញដូរមនុស្សអាចកើតមានគ្រប់ទិសទី ៣៩

មេរៀនទី ៥ ៖ ការរើសអើងភេទការដាក់ឲ្យស្រ្តី និងក្មេងស្រ្តីស្ថិតក្នុងហានិភ័យនៃ ការជួញដូរមនុស្ស ៥៥

មេរៀនទី ៦៖ ឥទ្ធិពលនៃគ្រឿងញៀន និងគ្រឿងស្រវឹងក្នុងការជួញដូរមនុស្ស ៦០

មេរៀនទី ៧៖ ការជួញដូរពលកម្មកុមារ និងការកេងប្រវ័ញ្ចពលកម្ម ៧១

មេរៀនទី ៨ ៖ ការជួញដូរ ដើម្បីការកេងប្រវ័ញ្ចផ្លូវភេទ ៨១




មេរៀនទី ៩ ៖ កុំចាញ់បោកគេ! ៨៨

មេរៀនទី ១០ ៖ អនុសញ្ញាស្ដីពីសិទ្ធិកុមារ ១០០

មេរៀនទី១១៖ ច្បាប់ស្ដីពីការជួញដូរមនុស្ស និងសិទ្ធិមនុស្ស ១០៥

មេរៀនទី១២៖ ការធ្វើចំណាកស្រុកមានឯកសារស្របច្បាប់ ១១៥

**ផ្នែក"គ" បំណិនជីវិតដែលអាចជួយឲ្យបុគ្គលបង្កើតភាពស៊ាំ**

មេរៀនទី១៣៖ ជំនាញក្នុងការនិយាយ (ជំនាញក្នុងការប្រាស្រ័យទាក់ទង) ១២២

មេរៀនទី១៤៖ ការស្ដាប់បានល្អ (ជំនាញក្នុងការប្រាស្រ័យទាក់ទង) ១២៩

មេរៀនទី១៥៖ អារម្មណ៍ និងការគិត (ជំនាញគ្រប់គ្រងអារម្មណ៍) ១៣៧

មេរៀនទី១៦៖ ការគ្រប់គ្រងអារម្មណ៍របស់យើង (ជំនាញគ្រប់គ្រងអារម្មណ៍) ១៤៤

មេរៀនទី១៧៖ ជាអ្នកជួញដូរមនុស្ស ឬមិនមែន? ១៥១

មេរៀនទី៨៖ សុវត្ថិភាពអ៊ីនធើណេត - ការប្រើអ៊ីនធើណេតដោយសុវត្ថិភាព ១៥៩

**ផ្នែក"ឃ" ការធ្វើផែនការចំណាកស្រុកប្រកបដោយសុវត្ថិភាព** ១៦៧

មេរៀនទី១៩៖ ជំនាញក្នុងការធ្វើសេចក្ដីសម្រេចចិត្ត ១៦៩

មេរៀនទី២០៖ សិក្សាបន្ថែម ១៧៨

មេរៀនទី២១៖ ការសួរសំណួរ ១៨៣

មេរៀនទី២២៖ ការប្រើប្រាស់បញ្ជីត្រួតពិនិត្យការធ្វើចំណាកស្រុកដោយសុវត្ថិភាព ១៨៥

មេរៀនទី២៣ ៖ ការរក្សាសុវត្ថិភាពពេលធ្វើដំណើរ ១៩០

មេរៀនទី២៤៖ នៅពេលអ្នកទៅដល់ ១៩៨

មេរៀនទី២៥ ៖ អ្វីដែលត្រូវធ្វើប្រសិនបើអ្នកត្រូវបានគេជួញដូរ ២០៨

មេរៀនទី២៦ ៖ ការឆ្លុះបញ្ចាំង ផ្លូវឆ្ពោះទៅរកការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ២១៦

**ផ្នែក"ង" ការអនុវត្តសកម្មភាព**

មេរៀនទី២៧ ៖ ការចែករំលែកនូវអ្វីដែលអ្នកបានដឹងដល់អ្នកដទៃ ២២២

មេរៀនទី២៨ ៖ សកម្មភាពសហគមន៍ - ជំហានទី ១ ២៣៤

មេរៀនទី២៩ ៖ សកម្មភាពសហគមន៍ - ជំហានទី ២ ២៣៩

មេរៀនទី៣០ ៖ សកម្មភាពសហគមន៍ - ជំហានទី ៣ ២៤៥

មេរៀនទី៣១ ៖ សកម្មភាពសហគមន៍ - ជំហានទី ៤ ២៤៨



## កំណត់សម្គាល់អំពីពាក្យបច្ចេកទេស

ឆ្លងតាមឧបករណ៍នាវិកវៃឆ្លាត ពាក្យថា យុវជន គឺត្រូវបានប្រើដើម្បីសំដៅដល់យុវជនដែលខុសពីកុមារ។ បើទោះបីជាអង្គការទស្សនៈពិភពលោកចាត់ទុកមនុស្សគ្រប់គ្នាដែលមានអាយុក្រោម ១៨ឆ្នាំ ជាកុមារក៏ដោយ ក៏ឧបករណ៍នាវិកវៃឆ្លាតនេះប្រើពាក្យថា យុវជន និងក្លិបយុវជននាវិកវៃឆ្លាតដែរ ពីព្រោះឯកសារនេះមានគោលដៅសំដៅដល់ក្រុមអាយុពី ១២ - ១៧ ឆ្នាំ។

ពាក្យថា ជនរងគ្រោះ ប្រើដើម្បីបរិយាយពីអ្នកដែលត្រូវបានគេជួញដូរ។ នេះពីព្រោះ ដោយសារតែមានបំណងដើម្បីដាក់កំហុសទៅលើជនចំណាកស្រុក ដែលត្រូវបាន គេជួញដូរសម្រាប់អ្វីដែលបានកើតឡើងលើពួកគាត់។ ពាក្យថា ជនរងគ្រោះ ត្រូវបានប្រើដើម្បី សង្កត់ធ្ងន់ថា ជនចំណាកស្រុកមិនទទួលខុសត្រូវសម្រាប់ការដែលត្រូវបានជួញដូរឡើយ។

ពាក្យថា ពេស្យាចារ ក៏ត្រូវបានប្រើនៅក្នុងឧបករណ៍នាវិកវៃឆ្លាតនេះដែរ។ ការប្រើពាក្យនេះពីព្រោះឧបករណ៍នាវិកវៃឆ្លាតនេះសង្កត់ធ្ងន់លើស្ថានភាព ដែលយុវជនត្រូវបានបង្ខំឲ្យ ធ្វើការងារនៅតាមផ្ទះបន ហើយនឹងត្រូវបានចាត់ទុកជាជនរងគ្រោះ។ ពាក្យថា អ្នកបម្រើ សេវាផ្លូវភេទ ចង់និយាយថា ការធ្វើការងារនៅក្នុងផ្ទះបនគឺជាការងារមួយ។ សម្រាបយុវជន ដែលត្រូវបានជួញដូរចូលទៅក្នុផ្ទះបន នេះមិនមែនជាការពិតទេ។ យុវជនទាំងនេះមិន ជ្រើសរើការងារនៅក្នុងផ្ទះបនទេ មិនអាចចាកចេញបាន និងជារឿយៗមិនទទួលបាន ប្រាក់កម្រៃនោះទេ។

ភាគច្រើននៃករណីសិក្សានៅក្នុងឧបករណ៍នាវិកវៃឆ្លាតនេះ គឺផ្អែកលើរឿងពិតនៃជីវិត របស់ជនចំណាកស្រុក។ ដើម្បីការពារអានាមិកភាព និងដើម្បីការពារការយល់ ច្រលំ អ្នកទាំងអស់ដែលមានបរិយាយនៅក្នុងករណីសិក្សាទាំងនេះ គឺប្រើតែអក្សរកាត់ឈ្មោះ ប៉ុណ្ណោះ។



# សេចក្ដីផ្ដើម

ក្លឹបយុវជននារីកវៃឆ្លាត (SNYC) គឺជាក្លឹបដែលត្រូវបានបង្កើតឡើងនៅកំរិតថ្នាក់ភូមិ ដើម្បីរួមចំណែកដល់ការកាត់បន្ថយហានិភ័យនៃការជួញដូរមនុស្សតាមរយៈការផ្ដល់ និងសិទ្ធិអំណាចដល់សមាជិកក្លឹបដើម្បីការពារខ្លួនឯង និងមិត្តភ័ក្តិរបស់ខ្លួន។ SNYC មានប្រតិបត្តិការនៅក្នុងប្រទេសចិន វៀតណាម ថៃ កម្ពុជា និង ភូមាសាធារណរដ្ឋប្រជាមានិតឡាវ ហើយក្លឹបទាំងនេះធ្វើការជាមួយនឹងក្រុមយុវជន ដែលងាយរងគ្រោះ អាយុចាប់ពី ១២ -១៧ ឆ្នាំ ដែលមកពីបណ្ដាសហគមន៍ដែលមានការធ្វើចំណាក់ស្រុក ឬការជួញដូរមនុស្សកម្រិតខ្ពស់។

សៀវភៅមគ្គុទេសនារីកវៃឆ្លាតនេះ សម្រាប់បណ្ដុះបណ្ដាលដល់យុវជន និងមនុស្សពេញវ័យ ផ្ដល់នូវព័ត៌មានដែលត្រូវការចាំបាច់សម្រាប់បង្កើត និងរៀបចំក្លឹបយុវជន។ សៀវភៅនេះរៀបរាប់អំពីក្របខ័ណ្ឌនៃក្លឹបយុវជន និងផ្ដល់នូវសេចក្ដីណែនាំសម្រាប់ការរៀបចំ និងការចាប់ផ្ដើមក្លឹបយុវជន។ ដើម្បីផ្ដួចផ្ដើម និងបង្កើតក្លឹបយុវជនមួយបាន ដៃគូរបស់អង្គការទស្សនៈពិភពលោក រួមជាមួយនឹងសហគមន៍ក្នុងមូលដ្ឋានត្រូវកំណត់អ្នកចូលរួមដែលអាចមាន និងអ្នកសម្របសម្រួល។

មុនពេលចាប់ផ្ដើមនៃវគ្គសិក្សាក្នុងក្លឹប បុគ្គលិករបស់អង្គការទស្សនៈពិភពលោក អ្នកសម្របសម្រួលពី SNYC និងឪពុកម្ដាយរបស់យុវជនត្រូវជួបជុំគ្នាទាំងអស់ ដើម្បីពិភាក្សាខ្លឹមសារនៃឧបករណ៍នារីកឆ្លាតនេះសិន។ អ្នកពាក់ព័ន្ធទាំងនេះសម្រេចចិត្តទាំងអស់គ្នា ថាតើមានប្រធានបទណាដែលរសើបខ្លាំងដោយចាំបាច់ត្រូវដកចេញដោយកត្តាអាយុ ឬភាពរំជើបរំជួលនៃវប្បធម៌នៃក្រុមជាក់លាក់ណាមួយដែរ ឬទេ។ ទាំងឪពុកម្ដាយ/អាណាព្យាបាល និងយុវជនផងដែរ នៅក្នុងដំណាក់កាលនេះ ត្រូវបានសុំឲ្យចុះហត្ថលេខាលើទម្រង់ពាក្យស្ដីពីការយល់ព្រម ប្រសិនបើគាត់ចង់ចូលរួមក្នុងក្លឹបនេះ។ អ្នកពាក់ព័ន្ធទាំងនេះក៏ជាអ្នកដែលត្រូវរៀបចំកម្មវិធីសម្រាប់ការជួបជុំរបស់ក្លឹបផងដែរ ដោយផ្អែកលើតម្រូវការរបស់យុវជន។ ជាការល្អនោះ SNYC នឹងត្រូវជួបគ្នារយៈពេល ៧៥ នាទី ម្ដងក្នុងមួយសប្ដាហ៍ ក្នុងអំឡុងពេលពី ៨-១៦ ខែ។ ប៉ុន្តែទោះជាយ៉ាងណា ឧករណ៍នេះ ក៏អាចសម្រួលដើម្បីបង្រៀននៅក្នុងសិក្ខាសាលាបន្ថែមផ្សេងទៀតដែលមានរយៈពេលច្រើនថ្ងៃជាប់ៗគ្នាបានផងដែរ ដើម្បីតម្រូវទៅតាមយុវជនមួយចំនួនដែលមិនអាចមានលទ្ធភាពចូលរួមក្នុងការប្រជុំតាមកម្មវិធីប្រចាំសប្ដាហ៍។

បន្ទាប់មកទៀត ឧបករណ៍នារីកវៃឆ្លាតត្រូវបានអនុវត្តដោយមនុស្សពេញវ័យ ដែលបានបណ្ដុះបណ្ដាលរួច និងអ្នកសម្របសម្រួលជាយុវជន ដែលធ្វើការជាអ្នកស្ម័គ្រចិត្ត។ ឧបករណ៍នេះមាន ៣១ មេរៀនដែលមានសកម្មភាពមុនចាប់ផ្ដើមមេរៀននីមួយផងដែរ។ ឧបករណ៍នេះជួយដល់យុវជនឲ្យកសាងទាំងចំណេះដឹង និងជំនាញ។ យុវជនអភិវឌ្ឍចំណេះដឹងពាក់ព័ន្ធនឹងគ្រោះថ្នាក់នៃការជួញដូរមនុស្ស ច្បាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងជំហានច្បាស់លាស់នានាដែលគេត្រូវអនុវត្តដើម្បីការពារខ្លួនគេ ដូចជាការបង្កើតបណ្ដាញគាំទ្រមួយ ឬការសិក្សាអំពីរបៀបនៃការទទួលបានលេខទូស័ព្ទផ្ដល់ជំនួយជាដើម។ ជាមួយគ្នានេះដែរ យុវជនរៀនសូត្រពីរបៀប នៃការអនុវត្តបំណិនជីវិតជាក់លាក់មួយចំនួនចំពោះដំណើររឿង អំពីការជួញដូរមនុស្សដើម្បីកសាងសមត្ថភាពងើបឡើងវិញរបស់ខ្លួនផងដែរ។

អមជាមួយនឹងឯកសារនេះ ក៏មានកូនសៀវភៅនារីកវៃឆ្លាតមួយផ្សេងទៀតផងដែរ ដែលនឹងត្រូវផ្ដល់ជូនសមាជិកនៃក្លឹបយុវជនគ្រប់រូបផងដែរ។ វាមានទំហំប៉ុនលិខិតឆ្លងដែនមួយ និងមានព័ត៌មានសំខាន់ៗអំពីការធ្វើចំណាក់ស្រុកដែលយុវជនអាចទុកជាឯកសារយោងបាន។

# ផ្នែក ក

# ការរៀបចំបង្កើតក្លឹបយុវជននាវីកវៃឆ្លាត



# ទម្រង់យល់ព្រម ៖ សម្រាប់ឪពុកម្តាយ ឬ អ្នកថែទាំសមាជិកក្លឹបយុវជននាវិកវៃឆ្លាត



## សេចក្តីណែនាំអំពីការប្រើប្រាស់

ទម្រង់យល់ព្រមរបស់ឪពុកម្តាយ/អ្នកផ្តល់ការថែទាំ គួរត្រូវបានចុះហត្ថលេខាជាមុនសិន មុននឹងយុវជនម្នាក់ចូលរួមក្នុងក្លិបយុវជន ។ ប្រសិនបើអ្នកបានសម្រេចចិត្តដកចេញនូវមេរៀនមួយ ចំនួនដូចដែលលទ្ធផលនៃសិក្ខាសាលាដំបូងដូច្នេះអ្នកអាចឆូតចោលនូវមៀរៀនទាំងនេះលើទម្រង់នេះមុនពេលផ្តល់ទៅឲ្យឪពុកម្តាយ/អ្នកផ្តល់ការថែទាំដើម្បីចុះហត្ថលេខា។

បោះពុម្ពទម្រង់យល់ព្រមដែលបានផ្តល់ឲ្យ ពន្យល់ពីមាតិការនិមួយៗដល់ឪពុកម្តាយ និងយុវជនដើម្បីឲ្យពួកគាត់យល់អំពីអ្វីដែលគាត់ឯកភាព ហើយបន្ទាប់មកទៀតឲ្យពួកគាត់ចុះហត្ថលេខា។ ទុកដាក់ទម្រង់ដែលបានចុះហត្ថលេខារួចនៅក្នុងទូសុវត្ថិភាពមួយ ។

## ទម្រង់យល់ព្រម

ក្លឹបយុវជននេះអញ្ជើញ ឲ្យមានការចូលរួមពីកូនរបស់អ្នកក្នុងការប្រជុំក្នុងក្លឹបរៀងរាល់សប្តាហ៍ ឬពីរដងក្នុងមួយខែដែលគេនឹងចូលរួមក្នុងសកម្មភាពគួរអោយចាប់អារម្មណ៍ និងទាក់ទាញជាមួយយុវជនពី ២០-៣០ នាក់ផ្សេងទៀតនៅក្នុងបរិយាកាសដែលមានសុវត្ថិភាពមួយ។ ការប្រជុំក្លឹបនឹងត្រូវធ្វើឡើងដោយប្រធានក្រុមជាមនុស្សពេញវ័យដែលត្រូវបានបណ្តុះបណ្តាល ហើយប្រធានក្រុមយុវជននឹងដឹកនាំឲ្យធ្វើការហ្វឹកហាត់ ខ្លះៗផងដែរ។ ការប្រជុំក្លឹបនឹងធ្វើឡើងក្នុងអំឡុងរយៈពេលប្រហែលជា ៨ ខែ។

- ក្លឹបនេះនឹងផ្តល់ឲ្យកូនរបស់អ្នកនូវព័ត៌មានអំពី៖
  - បំណិនជីវិត រួមមានការទំនាក់ទំនងល្អ និងការគ្រប់គ្រងអារម្មណ៍
  - អំពើជួញដូរមនុស្ស
  - ការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទលើយុវជន
  - តួនាទីរបស់ផ្ទះបនក្នុងការជួញដូរមនុស្ស
  - ច្បាប់ស្តីពីការជួញដូរមនុស្ស និងសិទ្ធិមនុស្ស
  - ការរើសអើងយេនឌ័ និងការជួញដូរមនុស្ស
  - គ្រោះថ្នាក់នៃគ្រឿងញៀន គ្រឿងស្រវឹង និងការជួញដូរមនុស្ស
  - ការរៀបចំផែនការសម្រាប់ការធ្វើចំណាកស្រុកដោយសុវត្ថិភាព
  - ការចូលរួមរបស់កូនអ្នកនៅក្នុងក្លិបគឺជាការស្ម័គ្រចិត្ត។ អ្នកអាចយកកូនអ្នកចេញវិញបានគ្រប់ដំណាក់កាលទាំងអស់ ។
- ក្នុងអំឡុងពេលនៃការប្រជុំក្លឹប កូនរបស់អ្នកអាចជ្រើសរើសឆ្លើយតែសំណួរណាដែលគេចង់ឆ្លើយតែប៉ុណ្ណោះ។ ប្រសិនបើកូនរបស់អ្នកមិនចង់និយាយ គឺគេអាចនៅស្ងៀមបាន។
- កូនអ្នកមិនចាំបាច់ត្រូវតែចូលរួម ក្នុងព្រឹត្តិការណ៍ ជាសកម្មភាពរបស់សហគមន៍ នៃក្លឹបនេះនោះទេ។ អ្នកអាចយកកូនអ្នកចេញវិញបានគ្រប់ដំណាក់កាលទាំងអស់។
- ប្រសិនបើកូនរបស់អ្នកសម្រេចចិត្តចូលរួមក្នុងព្រឹត្តិការណ៍ ក្នុងសកម្មភាពរបស់សហគមន៍គឺគេអាចជ្រើសជួយកិច្ចការដោយប្រយោគបាន ហើយមិនបាច់ចូលរួមក្នុងព្រឹត្តិការណ៍ដោយផ្ទាល់ក៏បាន។

**សូមអាន និងចុះហត្ថលេខាលើផ្នែកនេះសិន មុននឹងការចាប់ផ្តើមការប្រជុំក្លឹបយុវជននារីកវៃឆ្លាត ។**

ខ្ញុំបានអាន ហើយយល់អំពីព័ត៌មាន ក្នុងទម្រង់យល់ព្រមនេះរួចហើយ។ កូនរបស់ខ្ញុំអាចចូលរួមនៅក្នុងក្លឹបបាន។ ហើយខ្ញុំយល់ថា ខ្ញុំអាចយកកូនខ្ញុំចេញវិញបានគ្រប់ពេល។

បាទ/ចាស ទេ

ឈ្មោះឪពុកម្តាយ/អាណាព្យាបាល ..............................................................

កាលបរិច្ឆេទ..............................................................

ហត្ថលេខា ..............................................................

ឈ្មោះកូន ..............................................................

ហត្ថលេខារបស់កូន ..............................................................

# ការប្រើប្រាស់ទម្រង់ត្រួតពិនិត្យខ្លួនឯង សម្រាប់អ្នកសម្របសម្រួល

**បន្ទាប់ពីបញ្ចប់មេរៀននីមួយៗ សូមបំពេញទម្រង់នេះដើម្បីវាយតម្លៃលើម៉ោងសិក្សា។ ទម្រង់នេះត្រូវបានបង្កើតឡើងមានលក្ខណៈជាបញ្ជីត្រួតពិនិត្យ ដូច្នេះអាចបំពេញបានលឿន។**

ទម្រង់នេះបំពេញបានតែអ្នកសម្របសម្រួលដែលពេញវ័យប៉ុណ្ណោះ។

ទម្រង់នេះអាចមានប្រយោជន៍ដូចជា ៖

- វាអាចប្រើជាឧបករណ៍មួយដើម្បីជួយដល់អ្នកសម្របសម្រួលចងចាំអំពីអ្វី ដែលគាត់បានរៀនសូត្រពីការប្រជុំក្លឹប។
- វាអាចជួយដល់អ្នកសម្របសម្រួលកែលម្អសម្រាប់បង្រៀននៅថ្ងៃក្រោយបាន។
- វាអាចជួយដល់អ្នកសម្របសម្រួល ឲ្យកំណត់បញ្ហា ដែលត្រូវពិភាក្សា ជាមួយនឹងអ្នកគ្រប់គ្រងរបស់ខ្លួនបាន។

អ្នកសម្របសម្រួល គួរមានភាពស្មោះត្រង់ក្នុងការបំពេញទម្រង់នេះ។ ទាំងនេះគឺមិនមែនជាការធ្វើតេស្តនោះទេ។ ទម្រង់ទាំងនេះមិនបានសួរពីឈ្មោះ ឬក្លឹបរបស់អ្នកសម្របសម្រួលនោះទេ។ មានន័យថា ប្រសិនបើអង្គការទស្សនៈពិភពលោកជ្រើសរើសប្រើប្រាស់ទម្រង់ខ្លះសម្រាប់ការវាយតម្លៃនៃ SNYC ក្នុងដំណាក់កាលណាមួយពេលបន្ទាប់នោះ អង្គការ ទស្សនៈពិភពលោកនឹង មិនអាចសម្គាល់បានថា ជាអ្នកសម្របសម្រួលណាម្នាក់ដែលបានបំពេញទម្រង់នេះ ឬមកពីក្លឹបណានោះទេ។ យើងធ្វើបែបនេះគឺដើម្បីលើកទឹកចិត្តឲ្យអ្នកសម្របសម្រួលមានភាពស្មោះត្រង់ ពីព្រោះវានឹងអាចឲ្យយើងផ្តល់នូវព័ត៌មានត្រឡប់ដើម្បីកែលម្អដល់ SNYC និងឯកសារ ឧបករណ៍នាវីកវៃឆ្លាត។

# ទម្រង់ត្រួតពិនិត្យខ្លួនឯង សម្រាប់អ្នកសម្របសម្រួល

**បំពេញទម្រង់នេះ បន្ទាប់ពីម៉ោងសិក្សានីមួយៗ**
**ចំណាយពេលប្រហែលជា ៥ នាទី។ (ត្រូវបានបំពេញដោយអ្នកសម្របសម្រួលផ្ទាល់)**

កាលបរិច្ឆេទ________________
ចំណងជើងមេរៀន________________________________________________
តើមានសមាជិកប៉ុន្មាននាក់ដែលបានចូលរួមក្នុងម៉ោងសិក្សា? ប្រុស________ស្រី________

ប្រសិនបើមានសមាជិកមួយចំនួនអវត្តមាន តើអ្នកដឹងពីមូលហេតុឬទេ? ☐ បាទ/ចាស់ ☐ ទេ
តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីដោះស្រាយបញ្ហានេះ?

តើអ្នកបានគ្របដណ្តប់គ្រប់ខ្លឹមសារទាំងអស់នៃម៉ោងសិក្សានេះ ឬទេ? ☐ បាទ/ចាស់ ☐ ទេ
ប្រសិនបើទេ សូមពន្យល់ពីមូលហេតុ។

តើបញ្ចប់មេរៀនទាន់ពេលដែរ ឬទេ? ☐ បាទ/ចាស់ ☐ ទេ
ប្រសិនបើមិន សូមពន្យល់ពីមូលហេតុ

តើអ្នកបានអនុវត្តតាមសេចក្តីណែនាំក្នុងឧបករណ៍នេះដែរ ឬទេ? ☐ បាទ/ចាស់ ☐ ទេ
ប្រសិនបើមិន សូមពន្យល់ពីមូលហេតុ។

តើអ្នកនិយាយប្រកបដោយថាមពលដែរ ឬទេ? ☐ បាទ/ចាស់ ☐ ទេ

តើអ្នកកំណត់ពេលវេលាក្នុងការជជែកដែរ ឬទេ? ☐ បាទ/ចាស់ ☐ ទេ

| | |
|---|---|
| តើយុវជនទាំងអស់ចូលរួមក្នុងសកម្មភាពទាំងឡាយដែរ ឬទេ? | ☐ បាទ/ចាស់☐ ទេ |
| តើយុវជនប្រើទំនាក់ទំនងបែបបដិសេធន៍ដើម្បីផ្ដល់គំនិតដែរ ឬទេ? | ☐ បាទ/ចាស់☐ ទេ |
| តើយុវជនដែលមិនអាចអានបានអាចចូលរួមបានដែរ ឬទេ? | ☐ បាទ/ចាស់☐ ទេ |
| តើយុវជនពិការ (ក្នុងករណីអាច) អាចចូលរួមបានដែរ ឬទេ?<br>តើដោយរបៀបណា?<br><br>ប្រសិនបើទេ សូមពន្យល់ពីមូលហេតុ។ | ☐ បាទ/ចាស់☐ ទេ |
| តើអ្នកសម្របសម្រួលជាយុវជនបានដឹកនាំសកម្មភាពណាមួយដែរឬទេ?<br>ប្រសិនបើទេ សូមពន្យល់ពីមូលហេតុ។ | ☐ បាទ/ចាស់ ☐ ទេ |
| តើសកម្មភាពអនុវត្តន៍ដូចការគ្រោងទុកដែរ ឬទេ?<br>ប្រសិនបើទេ សូមពន្យល់ពីមូលហេតុ។ | ☐ បាទ/ចាស ☐ ទេ |
| តើអ្នកចូលរួមបានបង្ហាញនូវការយល់ដឹងពីប្រធានបទដែរ ឬទេ?<br>ប្រសិនបើទេ សូមពន្យល់ពីមូលហេតុ។ | ☐ បាទ/ចាស ☐ ទេ |
| តើអ្នកជួបបញ្ហាដែរ ឬទេក្នុងអំឡុងពេលនៃម៉ោងបង្រៀន។<br>ប្រសិនបើមាន សូមរៀបរាប់ | ☐ បាទ/ចាស ☐ ទេ |
| តើអ្នកមានយោបល់អ្វីបន្ថែមទៀតដែរ ឬទេ?<br>ប្រសិនបើមាន សូមរៀបរាប់ | ☐ បាទ/ចាស ☐ ទេ |
| តើអ្នកមានអ្វីដែលអ្នកគ្រោង ដើម្បីធ្វើអោយមេរៀនបន្ទាប់ចាប់អារម្មណ៍ដែរ ឬទេ? | ☐ បាទ/ចាស ☐ ទេ |

# កសាងទំនាក់ទំនងក្រុម
## ល្បែងថាមពល

**សកម្មភាពទាំងនេះមានគោលដៅប្រើនៅពេលចាប់ផ្តើមនៃមេរៀនភាគច្រើន។**
**សកម្មភាពទាំងនេះ អាចនឹងត្រូវបានប្រើប្រាស់ច្រើនដងនៅក្នុងសៀវភៅឧបករណ៍នាវិកវ័ន្ឌាត។**

### ល្បែងថាមពលទី ១ ៖ ការបង្កើតជួរមួយ

**វត្ថុបំណង**
ដើម្បីជួយឲ្យអ្នកចូលរួមកសាងទំនាក់ទំនង មានភាពសប្បាយ និងបង្កើតថាមពល។

**ពេលវេលា**
ពី ៥-១០ នាទី

**សម្ភារៈ**
(អត់មាន)

**សកម្មភាព**

១. ចែកអ្នកចូលរួមជាក្រុមជាក្រុមមានគ្នាពី ៥-៦ នាក់។
២. សុំឲ្យក្រុមនីមួយៗរៀបចំសមាជិកក្រុមរបស់ខ្លួនដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ ដូចខាងក្រោម ៖
- កម្ពស់ (ពីទាបបំផុត ទៅខ្ពស់បំផុត)
- អាយុ (ពីចាស់ជាងគេ ទៅក្មេងជាងគេ)
- ទំហំជើង
- ចម្ងាយធ្វើដំណើរមកកាន់ក្លឹប
- ចំនួនបងប្អូនបង្កើត

៣. បន្ទាប់ពីឮសញ្ញាសមាជិកក្រុមនីមួយៗ ត្រូវរៀបខ្លួនឯងឲ្យត្រូវតាមលក្ខណៈវិនិច្ឆ័យហើយបន្ទាប់មកអង្គុយចុះ។
៤. ដើម្បីឲ្យមានការប្រកួតប្រជែងកាន់តែខ្លាំង សុំឲ្យសិក្ខាកាមបំពេញកិច្ចការនេះដោយមិននិយាយរកគ្នា។
៥. គ្រូតពិនិត្យមើលលើការរៀប។
៦. ក្រុមការងារដែលរៀបហើយមុនដោយការរៀបត្រឹមត្រូវទទួលបានពិន្ទុមួយ។
៧. នៅពេលដែលក្រុមនីមួយៗបានរៀនអំពីល្បែងនេះរួចសិក្ខាកាមអាចនឹងផ្តល់នូវឧទាហរណ៍អំពីលក្ខណៈវិនិច្ឆ័យបន្ថែម។

# ល្បែងពង្រឹងថ្នាក់ទី ២ ៖ ល្បែងបោះបាល់ឈ្មោះ

## ចំណុចបំណង

ដើម្បីជួយឲ្យរក្សាទុក ស្គាល់គ្នា កសាងទំនាក់ទំនង មានភាពសប្បាយ និងបង្កើនថាមពល។

## ពេលវេលា

ពី ៥-១០ នាទី

**សម្ភារៈ**

(កូនបាល់)

## សកម្មភាព

១. បង្កើតជារង្វង់មួយ

២. កាន់បាល់នៅក្នុងដៃរបស់អ្នក

៣. និយាយឈ្មោះរបស់អ្នកពេលកំពុងកាន់បាល់ បន្ទាប់មកនិយាយម្តងទៀងនៅពេលអ្នកបោះបាល់ទៅកាន់អ្នកផ្សេងទៀត។

៤. បន្តធ្វើបែបនេះរហូតអ្នកទាំងអស់នៅក្នុងក្រុមបាននិយាយឈ្មោះរបស់ខ្លួនគ្រប់គ្នា។

៥. បន្ទាប់មកទៀត ធ្វើសកម្មភាពដដែល ប៉ុន្តែឲ្យអ្នកដែលកាន់បាល់និយាយឈ្មោះរបស់ខ្លួន ហើយនៅពេលបោះបាល់ ត្រូវហៅឈ្មោះអ្នកដែលទទួលបាល់។ ធ្វើបែបនេះរហូត ទាល់តែអ្នកទាំងអស់គ្នានៅក្នុងក្រុមបានធ្វើគ្រប់គ្នា។

៦. ប្រសិនបើនៅមានពេល គឺសិក្ខាកាមអាចនិយាយឈ្មោះរបស់ខ្លួន និងនិយាយអ្វីផ្សេងទៀតដែលគេចង់និយាយ។ ល្បែងនេះ អាចលេងបានអាស្រ័យទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗ (និយាយពីផ្លែឈើដែលអ្នកចូលចិត្ត ល្បែងបាល់ ចម្រៀង ។ល។)

# ល្បែងពង្រឹងថ្នាក់ទី ៣ ៖ អ្វីដែលអ្នកអាចនឹងមិនស្គាល់

**ទិសដៅបំណង**

ដើម្បីជួយឲ្យអ្នកចូលរួម ស្គាល់គ្នា កសាងទំនាក់ទំនង មានភាពសប្បាយ និងបង្កើនថាមពល។

**ពេលវេលា**

ពី ៥-១០ នាទី

**សម្ភារៈ**

(គ្មាន)

**សកម្មភាព**

១. សុំឲ្យសិក្ខាកាមឈរជាជួរមួយ

២. សុំឲ្យសិក្ខាកាមម្នាក់ដើរទៅកាន់ចុងម្ខាងទៀតនៃបន្ទប់ ហើយបន្ទាប់មកផ្តល់ឧទាហរណ៍អ្វីមួយ អំពីខ្លួនគាត់ដែលអ្នកផ្សេងអាចនឹងមិនដឹង។

ឧទាហរណ៍ ៖

- ខ្ញុំបានទៅលេងរាជធានីម្តង។
- ខ្ញុំចូលចិត្តការ៉េម
- ខ្ញុំអាចញាក់ត្រចៀកបាន
- ខ្ញុំធ្វើជាអ្នកចាំទីបាល់ទាត់

៣. អ្នកផ្សេងទៀតដែលមានរឿងដូចគ្នានោះត្រូវរត់ចូលមកជាមួយអ្នកទី1

៤. បន្ទាប់មកពួកគេទាំងអស់ត្រូវត្រឡប់មកកន្លែងដើមវិញ។

៥. ធ្វើបែបនេះដដែលៗឲ្យបានច្រើនតាមដែលអាចធ្វើបានអាស្រ័យលើពេលដែលមាន ។

# ល្បែងពង្រឹងថ្នាក់ទី ៤ ៖ ល្បែងបាល់ចងចាំ

**វត្ថុបំណង**

ដើម្បីជួយឲ្យអ្នកចូលរួម ស្គាល់គ្នាកសាងទំនាក់ទំនង មានភាពសប្បាយ និងបង្កើនថាមពល ល្បែងនេះត្រូវបានលេងដើម្បីរំឭក ឡើងវិញអំពីប្រធានបទដែលបានពិភាក្សាគ្នាពីមុនផងដែរ។

**ពេលវេលា**

ពី ៥-១០ នាទី

**សម្ភារៈ**

(កូនបាល់)

**សកម្មភាព**

១. បែងចែកជាក្រុមដែលមានគ្នាបួននាក់។

២. ក្រុមនីមួយៗឈរជារង្វង់ជិតៗគ្នាជាមួយក្រុមដ៏ទៃទៀត ។

៣. បោះបាល់ទៅឲ្យក្រុមមួយ។ សួរសំណួរទៅក្រុមនោះដែលយកចេញពី បញ្ជីសំនួរនៃល្បែងថាមពលទី៥។ អ្នកទាំងបួននាក់នៅក្នុងក្រុមពិភាក្សគ្នាដើម្បីសម្រេចយក ចម្លើយដែលត្រឹមត្រូវ។

៤. ប្រសិនបើក្រុមឆ្លើយចម្លើយត្រូវ ទទួលបានពិន្ទុមួយ បើមិនត្រូវទេបានពិន្ទុសូន្យ។

៥. បន្តធ្វើបែបនេះរហូតទាល់តែសួរសំណួរទាំងអស់។

# ល្បែងពង្រឹងថ្នាក់ទី ៥ ៖ ល្បែងសួរសំណួរខ្លី

**បំណង**

ដើម្បីជួយឲ្យអ្នកចូលរួម រំឭកឡើងវិញអំពីខ្លឹមសារដែលបានលើកឡើងនៅក្នុងមេរៀនពីមុនក្នុងលក្ខណៈកំសាន្តសប្បាយ។

**សម្ភារៈ**

(សំនួរខ្លី)

(រង្វាន់តូចៗ)

**ពេលវេលា**

ពី ៥-១០ នាទី

ល្បែងនេះមិនចាំបាច់សួរគ្រប់សំណួរទាំងអស់នៅក្នុងតារាងសំណួរទេ។ អ្នកសួរសំណួរច្រើនប៉ុណ្ណាតាមពេលវេលាដែលមាន។ មានសំណួរច្រើននៅក្នុងតារាងនេះ ដូច្នេះអ្នកអាចលេងល្បែងនេះបានច្រើនដង ដោយសំណួរផ្សេងៗ។ សំណួរមានបង់លេខ ហើយចម្លើយមាន នៅក្នុងចំណុចមូល និងសរសេរជា អក្សរទ្រេត ។ មានសំណួរ និងចម្លើយនៅទីនេះដែលហាក់បីដូចជាមិនច្បាស់លាស់ ទាល់តែអ្នកបានអាននៅក្នុងម៉ោងសិក្សាដែលពាក់ព័ន្ធផ្សេងទៀត។ ប៉ុន្តែនៅពេលដែលអ្នកបានអានសៀវភៅណែនាំនេះទាំងមូល បញ្ហានេះ នឹងដឹងច្បាស់មិនខាន។ ដូច្នេះ សូមសួរតែសំណួរណាដែលពាក់ព័ន្ធនឹងមេរៀនណាដែលអ្នកបានបង្រៀនរួចបានហើយ (លេខម៉ោងសិក្សាមានផ្តល់ឲ្យបន្ទាប់ពីសំណួរនីមួយៗ)។ ប្រសិនបើក្រុមមួយផ្តល់ចម្លើយមិនត្រូវ ចូរជួយលើកទឹកចិត្ត។ មិនត្រូវបំបាក់មុខសិក្ខាកាមឡើយ។ នេះមិនមែន ជាការធ្វើសំណួរខ្លីនៅសាលានោះទេ។ គោលបំណង គឺដើម្បីកំសាន្តសប្បាយ។ ផ្តល់រង្វាន់ តិចតួចសម្រាប់ចម្លើយដែលត្រឹមត្រូវ។

**សំណួរ**

**១. តើការជួញដូរមនុស្សមានន័យដូចម្តេច? (ពីម៉ោងសិក្សាទី ៣)**

- **ការជួញដូរមនុស្ស** គឺជាការឆបោក ឬបង្ខិតបង្ខំមនុស្សឲ្យធ្លាក់ចូលទៅក្នុងទម្រង់ ការងារបែបកេងប្រវ័ញ្ច ជនរងគ្រោះនៃការជួញដូរពិបាកក្នុងការគេចចេញ។ ការជួញដូរមនុស្សជាធម្មតាគឺទាក់ទងនឹងការយកជនរងគ្រោះ ចេញពីកន្លែងដែលគេរស់នៅទៅកាន់កន្លែងផ្សេងទៀតដោយការបង្ខំ ដើម្បីកេងប្រវ័ញ្ច។ ប៉ុន្តែមានអ្នកខ្លះត្រូវបានគេជួញដូរដោយមិនបាច់ផ្លាស់កន្លែងផងដែរ។

**២. តើអ្វីជាភាពខុសគ្នារវាងការជួញដូរ និងការរត់ពន្ធមនុស្ស (ពីម៉ោងសិក្សាទី ៣)**

- ការជួញដូរមនុស្ស ខុសពីការរត់ពន្ធមនុស្ស។ នៅពេលមនុស្សត្រូវបានគេរត់ពន្ធ គឺគេជួលឲ្យមនុស្សម្នាក់ផ្សេងទៀតនាំពួកគេឆ្លងកាត់ព្រំដែនដោយខុសច្បាប់។ បើទោះបីជាជនដែលត្រូវគេរត់ពន្ធ ត្រូវបានគេផ្តល់ប្រាក់ឲ្យ ដើម្បីធ្វើដំណើរ ហើយអាចនឹងនៅជាប់បំណុលក្រោយពីធ្វើដំណើររួចក៏ដោយ គឺពួកគេនឹងមានសេរីភាពជាធម្មតានៅពេលដែលទៅដល់

គោលដៅ ។ អ្នកដែលត្រូវគេជួញដូរ មិនមានសេរីភាពទេ។ មនុស្សសុខចិត្តឲ្យគេរត់ពន្ធខុសច្បាប់។

**៣. តើការជួញដូរមនុស្សកើតមានឡើងនៅកន្លែងណា? (ពីម៉ោងសិក្សាទី ៤)**

• ការជួញដូរមនុស្សកើតមានគ្រប់ទីកន្លែង - នៅផ្ទះ ពេលធ្វើដំណើរ ឬនៅកន្លែងគោលដៅ។ ជនម្នាក់ដែលត្រូវគេជួញដូរមិនចាំបាច់ទាល់តែផ្លាស់ទីកន្លែងនោះទេ។

**៤. តើអ្វីខ្លះជាល្បិចទូទៅរបស់អ្នកជួញដូរមនុស្ស? (ពីម៉ោងសិក្សាទី ៥)**

• អ្នកជួញដូរធ្វើពុតជាអ្នកឈ្មួញកណ្តាលស្របច្បាប់ម្នាក់។

• អ្នកជួញដូរធ្វើពុតជាមិត្តភ័ក្តិម្នាក់ ឬធ្វើជាចង់ជួយ។

• អ្នកជួញដូរផ្តល់ប្រាក់ខែខ្ពស់។ ជាញឹកញាប់គឺប្រាក់ខែខ្ពស់ខុសពីធម្មតា។

• អ្នកជួញដូរ បង់ប្រាក់ចុះឈ្មោះ ចេញថ្លៃធ្វើដំណើរ ឲ្យជនចំណាកស្រុក ឬឲ្យប្រាក់ជនរងគ្រោះ ខ្ចីដើម្បីឲ្យប្រាកដថា ពួកគាត់មិនរត់ចោលការងារ។ អ្នកជួញដូរ ធ្វើឲ្យប្រាកដថា ជនរងគ្រោះជំពាក់ប្រាក់ខ្លួន។

• អ្នកជួញដូរដកយកឯកសារអត្តសញ្ញាណរបស់ជនចំណាកស្រុក ជាពិសេសលិខិតឆ្លងដែន។

• អ្នកជួញដូរកុហក់ថា យកជនចំណាកស្រុកទៅកន្លែងធ្វើការតាមគោលដៅ។

**៥. តើគ្រឿងញៀនផ្តល់ទុក្ខទោសដល់មនុស្សក្នុងរូបភាពណាខ្លះ? (ពីម៉ោងសិក្សាទី ៦)**

•វាអាចបង្កការបំផ្លាញរយៈពេលវែងដល់រាងកាយ-ធ្វើទុក្ខបេះដូង សួត ថ្លើម និងតម្រងនោម។

•មនុស្សអាចលេបថ្នាំញៀនច្រើនហួសកម្រិត (លើសដូស) ដោយកំហុសឆ្គង ហើយលទ្ធផលគឺស្លាប់។

•មនុស្សអាចនឹងឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗទៀត នៅពេលគេប្រើម្ជុលរួមគ្នាដើម្បីចាក់ថ្នាំញៀន។

• ថ្នាំញៀនអាចធ្វើឲ្យមនុស្សហ៊ានប្រថុយធ្វើអ្វីដែលធម្មតាគេមិនហ៊ានធ្វើ។

**៦. តើអ្វីជាជ្រុងទាំងបួននៃសិទ្ធិនៅក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC)? (ពីម៉ោងសិក្សាទី ១០)**

• ការរស់រានមានជីវិត

• ការការពារ

• ការអភិវឌ្ឍ

• ការចូលរួម

**៧. តើអ្វីខ្លះជាឧទាហរណ៍នៃការទំនាក់ទំនងបែបបដិសេធន៍? (ពីម៉ោងសិក្សាទី ១៣)**

• ឧទាហរណ៍មួយគឺនិយាយថា "អត់ទេ អរគុណ។ ខ្ញុំចង់នៅផ្ទះច្រើនជាងទៅក្រៅ។" ប៉ុន្តែសិក្ខាកាម នឹងគិតពីឧទាហរណ៍ផ្សេងទៀត ហើយអ្នកត្រូវតែសម្រេចចិត្តថា គេត្រូវ ឬខុស។

**៨. តើអ្វីខ្លះជាឧទាហរណ៍នៃការទំនាក់ទំនងបែបទទួលយក? (ពីម៉ោងសិក្សាទី ១៣)**

• ឧទាហរណ៍មួយគឺនិយាយថា "អត់បញ្ហា ខ្ញុំនឹងធ្វើអ្វីដែលអ្នកបាននិយាយ ប្រសិនបើអ្នកនឹងធ្វើជាមិត្តខ្ញុំ"។ ប៉ុន្តែសិក្ខាកាមនឹងគិតពីឧទាហរណ៍ផ្សេងទៀត ហើយអ្នកត្រូវតែសម្រេចចិត្តថា គេត្រូវ ឬខុស។

**៩. តើអ្វីខ្លះជាឧទាហរណ៍នៃការទំនាក់ទំនងបែបកាច? (ពីម៉ោងសិក្សាទី ១៣)**

• ឧទាហរណ៍មួយគឺនិយាយថា " ឈប់និយាយ ខ្ញុំស្អប់ឯងណាស់!" សិក្ខាកាមនឹងគិតពីឧទាហរណ៍ផ្សេងទៀត ហើយអ្នកត្រូវតែសម្រេចចិត្តថា គេត្រូវ ឬខុស។

**១០. តើអ្វីដែលនឹងធ្វើនៅពេលដែលអ្នកស្តាប់ឮបានច្បាស់? (ពីម៉ោងសិក្សាទី ១៤)**

• គិតអំពីអ្វីដែលគេកំពុងនិយាយ។

• សួរអំពីអ្វីដែលអ្នកមិនយល់។

• និយាយឡើងវិញដោយប្រើពាក្យខ្លួនឯងអំពីអ្វីគេទើបនិយាយ។

• គិតអំពីអ្វីដែលអ្នកចង់ដឹងបន្ថែម និងសួរសំណួរទៅតាមនោះ។

**១១.តើអ្នកអាចផ្តល់ឧទាហរណ៍អំពីទម្រង់នៃការគិតអវិជ្ជមានបានដែរឬទេ?(ពីម៉ោងសិក្សាទី១៥)**

• ការគិតជ្រុលនិយមពេក។

• ស្តីបន្ទោសខ្លួនឯង ។

• មើលឃើញតែអ្វីដេលអាក្រក់។

• ព្យាករណ៍ពីអនាគតមិនល្អ។

**១២. តើអ្នកនៅចាំពីជំហានទាំងបី សម្រាប់ដោះស្រាយបញ្ហាអារម្មណ៍អវិជ្ជមានដែរឬទេ?(ពីម៉ោងសិក្សាទី ១៦)**

• កត់សម្គាល់ថា តើអ្នកមានអារម្មណ៍ដូចម្តេច។

• ស្វែងយល់ថា ហេតុអ្វីបានជាអ្នកមានអារម្មណ៍បែបនេះ។

• ជ្រើសរើសយកសកម្មភាពអ្វីមួយដែលធ្វើឲ្យអ្នកមានអារមណ៍បានប្រសើរ ប៉ុន្តែមិនត្រូវបង្កទុក្ខទោសដល់អ្នកដទៃឡើយ។

**១៣. តើអ្នកអាចរៀបរាប់ពីជំហាន នៃគំរូក្នុងការធ្វើ សេចក្តីសម្រេចចិត្តដែរ ឬទេ? (ពីម៉ោងសិក្សាទី ១៩)**

• ជំហានទី ១. រៀបរាប់ពីការសម្រេចចិត្តរបស់អ្នកក្នុងលក្ខណៈជាសំណួរមួយ។

• ជំហានទី ២. សិក្សាបន្ថែមទៀត។

• ជំហានទី ៣. រៀបរាប់ពីជម្រើស។

• ជំហានទី ៤. វាយតម្លៃលើហានិភ័យ និងអត្ថប្រយោជន៍ផ្សេងៗទៀត។

• ជំហានទី ៥. ធ្វើការសម្រេចចិត្តរបស់អ្នក។

**១៤. តើអ្វីខ្លះដែលអ្នកអាចធ្វើបានដើម្បីមានសុវត្ថិភាពពេលធ្វើដំណើរ? (ពីម៉ោងសិក្សាទី ១៩)**

• បំពេញបញ្ជីត្រួតពិនិត្យរបស់អ្នកសិនមុននឹងចាកចេញ។

• ព្យាយាមយកឯកសារធ្វើដំណើរស្របច្បាប់ដូចជា លិខិតឆ្លងដែន ឬទិដ្ឋាការការងារ មុនពេលអ្នកចាកចេញ។

• ទុកច្បាប់ថតចម្លងនៃឯកសាររបស់អ្នកនៅផ្ទះរបស់អ្នក។ ប្រសិនបើអ្នកមានបញ្ហាអ្វី ឬបាត់បង់ឯកសាររបស់អ្នក ឯកសារនោះនឹងជួយអ្នកបាន។

• ធ្វើដំណើរដោយមានប្រាក់ជាប់ខ្លួនគ្រប់គ្រាន់ដើម្បីចំណាយលើការធ្វើដំណើរ ដើម្បីរស់នៅមួយរយៈពេលគ្មានការងារធ្វើ និងដើម្បីត្រឡប់ទៅផ្ទះវិញ។

• រក្សាកូនសៀវភៅរបស់អ្នក ឯកសារអត្តសញ្ញាណរបស់អ្នក និងប្រាក់ នៅក្នុងកន្លែងលាក់កំបាំងមានសុវត្ថិភាព។

• ធ្វើដំណើរជាក្រុម ជាមួយនឹងអ្នកចំណាកស្រុកផ្សេងទៀត ដូចអ្នកដែរ (វាពិបាកក្នុងការបោកប្រាស់មនុស្សច្រើននាក់ក្នុងពេលតែមួយ ហើយជាក្រុមមានន័យថា អ្នកមានមិត្តដើម្បីជួយគ្នាបាន)។

• ត្រូវមានការសង្ស័យលើជនចម្លែកនៅក្នុងការធ្វើដំណើរចំណាកស្រុករបស់អ្នក (គេអាចជាអ្នកជួញដូរមនុស្ស)។

• ប្រសិនបើមាននរណាម្នាក់បង្ខំអ្នកឲ្យប្រគល់ឯកសារឲ្យគេ សុំឲ្យអ្នកដំណើរផ្សេងទៀត ឬមន្ត្រីឲ្យជួយអ្នក។

• មិនត្រូវទៅតាមមនុស្សចម្លែក ដែលចូលមករកអ្នក ក្នុងពេលកំពុងធ្វើដំណើរចំណាកស្រុកឡើយ។

• ព្យាយាមប្រើប្រាស់សេវាធ្វើដំណើរសាធារណៈ ជៀសវាងការជិះរថយន្តឯកជន ឬ រថយន្តដឹកអ្នកដំណើរខ្នាតតូច។

**១៥. តើអ្វីជាទិដ្ឋាការ? (ពីម៉ោងសិក្សាទី ១២ និង ២៣)**

• ទិដ្ឋាការគឺជាត្រា ឬក្រដាស់ស្អិត បិទនៅជាប់ក្នុងលិខិតឆ្លងដែនរបស់អ្នកដែលអនុញ្ញាតិឲ្យអ្នកចូលទៅក្នុងប្រទេសផ្សេងទៀតបាន។

**១៦. តើទិដ្ឋាការការងារ និងទិដ្ឋាការទេសចរណ៍ខុសគ្នាអ្វីខ្លះ? (ពីម៉ោងសិក្សាទី១២ និង២៣)**

• ទិដ្ឋាការការងារ អនុញ្ញាតិឲ្យអ្នធ្វើការងារ ដោយស្របច្បាប់នៅក្នុងប្រទេសផ្សេង។ ទិដ្ឋាការទេសចរណ៍ អនុញ្ញាតិឲ្យអ្នកដើរទេស្សនាតែមួយមុខគត់ មិនអាចធ្វើការបានទេ។

**១៧. តើលិខិតឆ្លងដែនគឺជាអ្វី? (ពីម៉ោងសិក្សាទី១២ និង២៣)**

• លិខិតឆ្លងដែន គឺជាឯកសារដែលចេញឲ្យ ដោយរដ្ឋាភិបាលនៃប្រទេស របស់អ្នកដែលអនុញ្ញាតិ ឲ្យអ្នកអាចចេញ និងចូលប្រទេសរបស់អ្នកបាន។

**១៨. តើអ្វីជាលេខទូរស័ព្ទគ្រាអាសន្ននៅក្នុងប្រទេសរបស់អ្នក? (ពីម៉ោងសិក្សាទី២៥)**

• ចម្លើយសំណួរនេះគឺ "IS 25c : លេខទូរស័ព្ទគ្រាអាសន្ន" ប៉ុន្តែអ្នកសម្របសម្រួលក៏គួរតែលើកឡើងអំពីលេខនេះផងដែរ។

**១៩. តើអ្វីជាលេខទូរស័ព្ទគ្រាអាសន្ន នៅក្នុងប្រទេសគោលដៅ នៅក្បែរប្រទេសរបស់អ្នក? (ពីម៉ោងសិក្សាទី២៥)**

• ចម្លើយសំណួរនេះគឺ "IS 25c : លេខទូរស័ព្ទគ្រាអាសន្ន" ប៉ុន្តែអ្នកសម្របសម្រួលក៏គួរតែលើកឡើងអំពីលេខនេះផងដែរ។

# ល្បែងពង្រឹងថ្នាក់ទី ៦ ៖ ល្បែងលាក់កន្សែង

**វត្ថុបំណង**

ដើម្បីជួយឲ្យអ្នកចូលរួមមានភាពសប្បាយរីករាយ និងជាការបង្កើនថាមពល។

**ពេលវេលា**

ពី ៥-១០ នាទី

**សម្ភារៈ**

- ក្រណាត់ រឺក្រមា

**សកម្មភាព**

១. ពន្យល់ថា ល្បែងបន្ទាប់ គឺជាល្បែងប្រភេទថ្មី នៃល្បែងប្រពៃណី ដើម្បីឲ្យស្គាល់គ្នាបានកាន់តែច្បាស់។

២. អ្នកចូលរួមទាំងអស់អង្គុយជារង្វង់។

៣. អ្នកចូលរួមម្នាក់ដើរជុំវិញរង្វង់នេះ ហើយទម្លាក់កន្សែង ឬ ក្រណាតនៅកន្លែងអង្គុយរបស់អ្នកចូលរួមម្នាក់ (ល្បែងនេះក៏អាចលេងបានដោយការប៉ះស្មាជំនួយឲ្យការប្រើកន្សែង)

៤. បន្ទាប់មកទៀត អ្នកទី ២ រត់ដេញ អ្នកទី១ ជុំវិញរង្វង់។

៥. ប្រសិនបើអ្នកទីពីរចាប់អ្នកទីមួយបាន នោះអ្នកទីមួយនឹងត្រូវចាំទី ។

៦. ប្រសិនបើអ្នកទីពីរ មិនអាចចាប់អ្នកទីមួយបានទេនោះ អ្នកទីពីរត្រូវចាំទីម្តង។

# ១ មេរៀនទី ១ ៖ ការណែនាំអំពីក្លឹបរបស់យើង

**បំណង**

ដើម្បីជួយឲ្យអ្នកចូលរួមស្គាល់គ្នា រៀនបន្ថែមអំពី SNYC សរសេរអំពីវិន័យសម្រាប់ SNYC និងគ្រប់គ្រងការធ្វើតេស្តសាកល្បងមុនដើម្បីកំណត់ចំណេះដឹងរបស់អ្នកចូលរួមអំពីការជួញដូរមនុស្ស។

**ពេលវេលា**

៧៥ នាទី

**សម្ភារ:**

- ប៊ិចពិណា ១០ឈុត
- ផ្លាកឈ្មោះសំរាប់អ្នកចូលរួម
- ក្រដាសផ្ទាំងធំ
- ឯកសារថតចម្លង "IS ១: Pre=Test" សំរាប់អ្នកចូលរួមទាំងអស់

**ការត្រៀម**

មុនពេល អ្នកចាប់ផ្តើមមេរៀនដំបូងនៃ SNYC នេះត្រូវពិភាក្សា ជាមួយបុគ្គលិករបស់ អង្គការទស្សនៈពិភពលោកសិន ដើម្បីសម្រេចថា តើកម្រិតទី ១ ទី២ និងទី៣មួយណាសមស្របសម្រាប់ក្លឹបរបស់អ្នក។ មុនពេលអ្នកចាប់ផ្តើមម៉ោងសិក្សា SNYC ទីមួយនេះ ត្រូវរៀបសិក្ខាសាលាមួយជាមួយនឹងអ្នកសម្របសំរួលជាមនុស្សពេញវ័យ អ្នកសម្របសម្រួលជាយុវជន ឪពុកម្តាយ សិស្សយុវជន និងក្រុមអ្នកធ្វើសេចក្តី សម្រេចចិត្តនៅក្នុងសហគមន៍ដើម្បី ៖

- បង្កើតកាលវិភាគ
- ចុះហត្ថលេខាលើទម្រង់យល់ព្រម
- ផ្តល់ការសង្ខេប និងពិភាក្សាពីមាតិកាទាំងអស់ក្នុងមេរៀន

**អ្នកគួរ ៖**

- អានមេរៀនឡើងវិញមុនពេលអ្នកចាប់ផ្តើម
- រៀបចំត្រៀមសម្ភារៈនានាដែលត្រូវការចាំបាច់ រៀបចំសំភារៈដែលត្រូវការ
- មកដល់ថ្នាក់ឲ្យបានមុនដើម្បីធានាថា អ្នកបានត្រៀមខ្លួនរួចជាស្រេច

**សេចក្តីផ្តើម**

**ការស្វាគមន៍**

ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះរបស់គេ និងសុំឲ្យពួកគេចុះហត្ថលេខា។

**សកម្មភាពមុនចាប់ផ្តើម**

សុំឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំការលេង “ល្បែងបោះបាល់ប្រាប់ឈ្មោះ” ពីលំហាត់សកម្មភាពមុនចាប់ផ្តើម។

**ការរំឭកមេរៀន**

មិនមាន

## ក្លឹបយុវជននាវិកវៃឆ្លាត

ស្វាគមន៍ទៅកាន់ក្រុម និងណែនាំពីខ្លួនរបស់អ្នក។ ពន្យល់ថា ថ្ងៃនេះ អ្នកទាំងអស់គ្នានឹងណែនាំឲ្យស្គាល់គ្នា សិក្សាអំពី SNYC និងគិតអំពីជីវិតរបស់ខ្លួន ។

រំឭកដល់អ្នកចូលរួមអំពីបញ្ហានៃ SNYC ដែលត្រូវបានសម្រេចនៅក្នុងសិក្ខាសាលាជាមួយនឹងឪពុកម្តាយ/អ្នកផ្តល់ការថែទាំ យុវជន និងអ្នកសម្របសម្រួល រួមមានអំពីភាពញឹកញាប់ដែលក្លឹបនឹងជួបជុំ ពេលវេលាប្រជុំ និងអំពីថាតើនរណាខ្លះដែលត្រូវធ្វើជាអ្នកសម្របសម្រួល ។

ពន្យល់ថា ក្នុងអំឡុងពេលនៃវគ្គសិក្សានេះ មានប្រធានបទផ្សេងៗគ្នាជាច្រើននឹងត្រូវបានលើកមកពិភាក្សា។ ម៉ោងសិក្សានឹងចាប់ផ្តើម ដោយការណែនាំអំពីប្រធានបទការជួញដូរមនុស្ស ការពិភាក្សាអំពីអ្វីជាការជួញដូរ របៀបនៃការជួញដូរ និងទីកន្លែងដែលវាកើតឡើង។ បន្ទាប់មកអ្នកចូលរួម នឹងបានរៀនអំពីជំនាញសម្រាប់អភិវឌ្ឍខ្លួន។ ជំនាញទាំងនេះ គឺជាជំនាញសង្គមដែលគេប្រើ ដើម្បីជួយឲ្យមនុស្សមានសុវត្ថិភាព។

ពន្យល់ផងដែរថា អ្នកសម្របសម្រួលក៏នឹងពិភាក្សាអំពីមធ្យោបាយមួយចំនួនដើម្បីរក្សាសុវត្ថិភាពមុនពេលធ្វើចំណាកស្រុក ក្នុងពេលកំពុងធ្វើដំណើរ និងពេលទៅដល់គោលដៅ។

## ការប្តេជ្ញាចិត្ត

ពន្យល់ថា SNYC គឺមិនដូចគ្នានឹងសាលារៀនទេ។ គ្រប់មេរៀនទាំងអស់នឹងមានការលេងល្បែង ពេលសម្រាប់គូរគំនូរ និងឱកាសក្នុងការចូលរួមសម្តែងរឿង។ មេរៀនត្រូវបានបង្កើតឡើងដើម្បី កំសាន្តសប្បាយ កសាងមិត្តភាព និងបង្រៀនច្រើន។ វាមានសារៈសំខាន់ដល់អ្នកចូលរួមប្តេជ្ញាចិត្តថានឹងត្រូវចូលរួមគ្រប់មេរៀនទាំងអស់ដើម្បីរៀនសូត្រពីជំនាញ និងព័ត៌មានសំខាន់ៗទាំងអស់នោះ។

ពន្យល់ថា ដើម្បីបង្កើតការប្តេជ្ញាចិត្ត និងលើកកម្ពស់ការចូលរួមនោះ SNYC មានប្រព័ន្ធផ្កាយមួយ។ មាន ៣១ មេរៀននៅក្នុងឧបករណ៍នាវិកវៃឆ្លាតវៃ ដែលជួយលើកកម្ពស់ព្រឹត្តការណ៍សកម្មភាពសហគមន៍។ អ្នកចូលរួមនឹងទទួលបានផ្កាយមួយសម្រាប់គ្រប់មេរៀនដែលគេបានចូលរួម។ អ្នកចូលរួមដែលទទួលបានផ្កាយចំនួន ២២ នឹងមានសិទ្ធិទទួលបានរង្វាន់លើកទឹកចិត្តកម្រិត១ ហើយអ្នកចូលរួមដែលទទួលបានផ្កាយ ២៦ នឹងទទួលបានរង្វាន់លើកទឹកចិត្ត កម្រិត២ ហើយយុវជនដែលបានចូលរួមបានគ្រប់ទាំង ៣១ មេរៀនទាំងអស់នឹងមានសិទ្ធិទទួលបានរង្វាន់លើកទឹកចិត្តកម្រិត ៣។ អ្នកសម្របសម្រួលជាយុវជននឹងមានសិទ្ធិទទួលបានរង្វាន់លើកទឹកចិត្តដែរចំពោះការចូលរួម។

ពន្យល់ដល់សិក្ខាកាមថា អ្វីទៅជារង្វាន់កម្រិត ១ ២ និង៣ សម្រាប់ក្រុមរបស់អ្នក។ រង្វាន់ទាំងនេះនឹងប្រែប្រួលទៅតាមភូមិ។

## ផ្លាកឈ្មោះ

ចែកផ្លាកឈ្មោះ និងប៊ិច។ សុំឲ្យអ្នកចូលរួមសរសេរឈ្មោះរបស់គេនៅលើផ្លាកឈ្មោះនោះនិងគូរូបតូចៗដែលបង្ហាញពីអ្វីដែលគេចង់ធ្វើ។

## ការចូលរួមរបស់យុវជន

ពន្យល់ថា មួយក្នុងចំណោមជំនឿស្នូលរបស់អង្គការទស្សនៈពិភពលោក និង SNYC គឺថា យុវជន មានសិទ្ធិចំពោះការស្តាប់ សិទ្ធិក្នុងការបញ្ចេញមតិអំពីបញ្ហាដែលប៉ះពាល់ដល់ពួកគេនិង សិទ្ធិចំពោះសេរីភាពក្នុងការសម្តែងគំនិត ។

ពន្យល់ថា នេះគឺមានន័យថា យុវជននៅក្នុងក្លឹបនេះមានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ បើទោះបីជាខុសគ្នាពីមតិដែលបានបញ្ចេញរួចហើយក៏ដោយ និងមានសិទ្ធិចូលរួមក្នុង ការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងក្លឹប។ ពួកគេក៏មានសិទ្ធិក្នុងការសួរសំណួរផងដែរ ប្រសិនបើគេមិនយល់អំពីអ្វីមួយ។ នេះក៏ជាមូលហេតុផងដែរដែលថា ហេតុអ្វីបានជាត្រូវមានការប្រជុំមួយមុនពេល ក្លឹបចាប់ផ្តើមដើម្បីស្តាប់ពីមតិយោបល់របស់យុវជនពាក់ព័ន្ធទៅនឹងមាតិកានិងកាលវិភាគរបស់ក្លឹប។ ពន្យល់ថា អង្គការទស្សនៈពិភពលោក ក៏នឹងចង់បានផងដែរនូវមតិយោបល់របស់អ្នកសម្របសម្រួលតាមរយៈមេរៀនរបស់ក្លិប ហើយនឹងរៀបចំនូវព្រឹត្តិការណ៍មួយដើម្បីចែករំលែកគំនិតទាំងនោះក្រោយពេលមេរៀនត្រូវបានបញ្ចប់។

ពន្យល់ថា ឧបករណ៍នារីកវៃឆ្លាតនេះ នឹងផ្តល់នូវការទទួលបានព័ត៌មានដែលនឹងជួយដល់អ្នកចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តច្បាស់លាស់អំពីជីវិតរបស់គេផ្ទាល់។ ក្នុងអំឡុងពេលរៀន អង្គការទស្សនៈពិភពលោក សង្ឃឹមថា សមាជិករបស់ក្លឹបទាំងអស់នឹងប្រើប្រាស់ ព័ត៌មាន ចែករំលែកទស្សនៈរបស់ខ្លួន ចូលរួមក្នុងសកម្មភាពនានារបស់ក្លិប និង ចូលរួម។

## ការសរសេរវិន័យរបស់យើង

ពន្យល់ថា SNYC ត្រូវបានបង្កើតឡើងដើម្បីការកំសាន្តសប្បាយ ក៏ប៉ុន្តែក៏ជាកន្លែងដែលអ្នកចូលរួម គ្រប់គ្នាត្រូវបានគោរព និងប្រព្រឹត្តលើយ៉ាងល្អផងដែរ។ វិន័យអាចជួយឲ្យអ្នកចូលរួមធ្វើការរួមគ្នា។ ឧទាហរណ៍មួយនៃវិន័យនេះអាចជា "យើងត្រូវស្តាប់ចូលរួមជវដែកគ្នា ហើយយើង មិន ត្រូវព្យាយាមរំខានដល់អ្នកផ្សេងទេ" ។ សុំឲ្យចូលរួមគិតពីវិន័យមូលដ្ឋានផ្សេងទៀតសម្រាប់ក្រុម។ សរសេរយោបល់របស់ពួកគេនៅលើក្រដាសផ្ទាំងធំ។

ប្រសិនបើវិន័យខាងក្រោមមិនមានសិស្សលើកឡើងទេនោះ ចូរបញ្ចូលវាទៅក្នុងតារាង៖

- អ្វីដែលយើងអំពីខ្លួនយើង គឺជាការសម្ងាត់ និងនៅក្នុងក្រុម។ យើងមិនប្រាប់អ្នកផ្សេងអំពីអ្វីដែលមិត្តរបស់យើងបាននិយាយ ឬបានធ្វើនៅក្នុងឡើយ។
- អ្នកគ្រប់គ្នាមានសិទ្ធិមិននិយាយ និងមិនចូលរួម ប្រសិនបើគេមានអារម្មណ៍មិនស្រួល។
- អ្នកចូលរួមម្នាក់ត្រូវបានផ្តល់ឱកាសឲ្យមានមតិ។
- នៅពេលនរណាម្នាក់កំពុងនិយាយ អ្នកផ្សេងទៀតត្រូវស្តាប់។
- មិនមាននរណាម្នាក់វាយប្រហារ ឬធ្វើឲ្យប៉ះពាល់ដល់អារម្មណ៍អ្នកផ្សេងឡើយ។
- លើកលែងតែ ក្នុងករណីគ្រោះអាសន្ន បើមិនដូច្នេះ គឺយើងមិនត្រូវទទួលទូរស័ព្ទក្នុងអំឡុងម៉ោងសិក្សាឡើយ។
- យើងនឹងព្យាយាមឲ្យអស់ពីលទ្ធភាព ដើម្បីមកចូលរួមឲ្យបានគ្រប់ម៉ោង សិក្សា។

សុំឲ្យអ្នកចូលរួម ទាំងអស់ពិចារណាអំពីវិន័យខាងលើ។ តើវាចាំបាច់ដែរឬទេ?

តើមានន័យយល់បានដែរឬទេ? តើមើលទៅវាមានភាពយុត្តិធម៌ដែរ ឬទេ?

សុំឲ្យក្រុមអានឡើងវិញលើតារាងខាងលើ និងបោះឆ្នោតជ្រើសរើសថា វិន័យណាខ្លះដែលនឹងត្រូវរក្សាទុក។ព្យួរតារាងវិន័យនៅនឹងជញ្ជាំងត្រង់កន្លែង ដែលទាំងអស់អាចមើលឃើញ។ សុំឲ្យសិស្សចុះហត្ថលេខា ឬគូររូបអ្វីមួយតំណាងឲ្យខ្លួនគេ នៅលើតារាងធ្វើជាសញ្ញានៃយោបល់របស់គេចំពោះក្លឹប។ អ្នកសម្របសម្រួលត្រូវចុះហត្ថលេខាលើតារាងវិន័យនេះដែរ និងសន្យាគោរពតាមគ្រប់ពេល។ ព្យួរតារាងវិន័យនៅនឹងជញ្ជាំងពេលចាប់ផ្តើមមេរៀននៃ SNYC នីមួយៗ។

ពន្យល់ថា ចំពោះនរណាម្នាក់ដែលបំពានលើវិន័យណាមួយនៃវិន័យនេះ អ្នកចូលរួមផ្សេងទៀតដែលចង់អាចចង្អុលទៅតារាងយ៉ាងទន់ភ្លន់ដើម្បីរំឭកដល់អ្នកចូលរួមដែលខុសនោះ។

*ចំណាំសម្រាប់អ្នកសម្របសម្រួល* ៖ ក្នុងវប្បធម៌មួយចំនួន វាអាចជាការសមស្របក្នុងការទទួលទោសពេលធ្វើខុសវិន័យ។ ឧទាហរណ៍ដូចជា អ្នកអាចឲ្យអ្នកបំពានវិន័យនោះច្រៀង ចម្រៀងលេងសើច ឬរាំបែបលេងសើចបាន។ ទោះជាយ៉ាងណា ធ្វើបែបនេះបានតែក្នុងករណីដែលយុវជន គិតថា វាជាការកំសាន្តសប្បាយប៉ុណ្ណោះ។កុំបង្អាប់យុវជនឡើយ ចូរចងចាំថាវិន័យនេះមិនមែនជាក់ទណ្ឌកម្មទេ វិន័យទាំងនេះមានអត្ថប្រយោជន៍ តែក្នុងករណី ដែលអ្នកចូលរួម ទាំងអស់បានជួយក្នុងការធ្វើឲ្យក្រុមមានសុខដុមនីយកម្មប៉ុណ្ណោះ។ ពួកគេគួរតែបង្កើត បរិយាកាសល្អមួយនៅក្នុងក្លឹប។

ពន្យល់ថា នេះគឺជារឿងមួយទៀតដែលត្រូវពិភាក្សាគ្នា។ តាមរយៈឧបករណ៍នាវិកវៃឆ្លាតនេះប្រធានបទពិបាកៗនឹងត្រូវបានពិភាក្សា ៖ នៅមានទិដ្ឋភាពមួយចំនួនដែលពេលខ្លះមនុស្សធំធ្វើទុក្ខទោសយុវជន។ អង្គការទស្សនៈពិភពលោកជឿជាក់ថា យុវជនមានសិទ្ធិរស់នៅប្រកបដោយមិនមានអំពើហិង្សា និងការកេងប្រវ័ញ្ច។ ពន្យល់ថា ប្រសិនបើមនុស្សធំនឹងធ្វើទុក្ខទោសដល់គេនោះ អ្នកចូលរួមអាចនិយាយជាមួយនឹងអ្នកសម្របសម្រួលរបស់ក្លឹបអំពីបញ្ហានេះបាន។ អ្នកសម្របសម្រួលនឹងទាក់ទងទៅកាន់បុគ្គលិកអង្គការទស្សនៈពិភពលោកដើម្បីចាត់វិធានការការពារដល់ពួកគេ។

## ការរៀបចំសំណួរសាកល្បងមុនវគ្គបណ្តុះបណ្តាល

ពន្យល់ថា គោលបំណងនៃការធ្វើសំណួរសាកល្បងមុនបណ្តុះបណ្តាលនេះគឺដើម្បីវាស់វែងការបម្រែបម្រួល ចំណេះដឹង និងអាកប្បកិរិយារបស់អ្នកចូលរួមដោយសារលទ្ធផលនៃកការបណ្តុះបណ្តាល ។ ការ រំពឹងទុកគឺថា យុវជននៅក្នុងក្លឹបនេះ នឹងមិនដឹងច្រើនអំពីប្រធានបទទាំងនេះទេ មុនពេលពួកគេចាប់ផ្តើមវគ្គបណ្តុះបណ្តាលនេះ។ ត្រូវប្រាកដថា ពួកគេមិនមានអារម្មណ៍អាក់អន់ស្រពន់ចិត្ត ឬអាមាស់មុខចំពោះការមិនដឹងចម្លើយសំណួរទាំងនោះទេ។ នេះហើយជាមូលហេតុដែលជាការសំខាន់គឺត្រូវអានសេចក្តីណែនាំនៃការធ្វើតេស្តនេះសិន។ បរិយាកាសនៅក្នុងថ្នាក់គួរមានលក្ខណៈរសាយ និងកក់ក្តៅ។

ការធ្វើតេស្តនេះមានគោលបំណងដើម្បីវាយតម្លៃថា តើយុវជនដឹងអំពីមុខវិជ្ជានេះកម្រិតណា។ គឺមិនមានបំណងធ្វើតេស្តដើម្បីដឹងថា ពួកគេធ្វើបានល្អកម្រិតណាក្នុងការអាន និងសរសេរនោះទេ។ ប្រសិនបើមានអ្នកចូលរួមដែលពិបាកក្នុងការអាន ឬសរសេរនោះអ្នកសម្រប

សម្រួលអាចអានសំណួរឲ្យគេ និងសរសេរចម្លើយរបស់គេឲ្យគេតែម្តង។

រក្សាទុកឯកសារធ្វើតេស្តមុនបណ្តុះបណ្តាលទាំងអស់នៅក្នុងកន្លែងមានសុវត្ថិភាព។ អ្នកនឹងត្រូវការប្រៀបធៀបជាមួយនឹងការធ្វើតេស្ត ក្រោយបណ្តុះបណ្តាលនៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ។

## ការធ្វើតេស្តមុនបណ្តុះបណ្តាល

ចូរអានអក្សរខាងក្រោមឲ្យអ្នកចូលរួមស្តាប់ ។

"សូមស្វាគមន៍! យើងនឹងត្រូវបំពេញទម្រង់មួយដើម្បីដឹងថា តើអ្នកដឹងអំពីប្រធានបទទាំងនេះ កម្រិតណានៅក្នុងវគ្គបណ្តុះបណ្តាលនេះ។ ទម្រង់មួយនេះគឺសម្រាប់អង្គការទស្សនៈពិភពលោក ដូច្នេះយើងអាចធ្វើការកែលម្អវគ្គបណ្តុះបណ្តាលរបស់យើងបាន។ វាមិនអីនោះទេ ប្រសិនបើ អ្នកមិនដឹង ចម្លើយសំណួរណាមួយនោះ។ គោលបំណងនៃវគ្គបណ្តុះបណ្តាលនេះគឺដើម្បី បង្រៀនអ្នកអំពីចម្លើយទាំងនេះ។ យើងគ្រាន់តែសុំឲ្យអ្នកបំពេញទម្រង់នេះដើម្បីយើងអាចវាស់វែងអំពីអ្វីដែលអ្នកដឹងនៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាលជាមួយនឹងអ្វីដែលអ្នកចេះនៅពេល បញ្ចប់វគ្គប៉ុណ្ណោះ។

ប្រសិនបើអ្នកចង់ឲ្យអ្នកសម្របសម្រួលអានសំណួរឲ្យអ្នក និងសរសេរចម្លើយឲ្យនោះ សូមប្រាប់អ្នកសម្របសម្រួលឲ្យបានដឹង"។

ចែកក្រដាស "IS 1៖ ការធ្វើតេស្តវាស់សមត្ថភាព" ទៅឲ្យអ្នកចូលរួម ឬអង្គុយជាមួយអ្នកចូលរួមម្តងម្នាក់ដើម្បីអាន និងកត់ចម្លើយ។ ប្រមូលទុកក្រដាសធ្វើតេសនៅពេលដែលអ្នកចូលរួមបានបញ្ចប់ និងរក្សាក្រដាសនេះទុក ដើម្បីប្រៀបធៀបជាមួយនឹងការតេស្ត ក្រោយវគ្គបណ្តុះបណ្តាលនៅពេលបញ្ចប់វគ្គ។

## ការបិទវគ្គ

នៅពេលចុងបញ្ចប់នៃការប្រជុំក្លឹប ជាការល្អក្នុងការផ្តល់ឱកាសសម្រាប់អ្នកចូលរួមឲ្យស រសេរ ឬ សួរសំណួរខ្លះៗនិង/ឬផ្តល់ព័ត៌មានត្រឡប់ និងប្រគល់ឲ្យអ្នកសម្របសម្រួល។ សំណួរ យោបល់ទាំងនេះ អាចប្រមូលដោយអនាមិកបាន ហើយនឹងផ្តល់ឲ្យអ្នកសម្របសម្រួលនូវគំនិតខ្លះអំពីថា តើប្រធានបទណាខ្លះដែលត្រូវការបញ្ជាក់បន្ថែម ឬដោះស្រាយ។ អ្នកសម្របសម្រួលអាចឆ្លើយតបទៅនឹងកង្វល់/សំណួរនៅម៉ោងក្រោយ ឬគ្រោងឆ្លើយនៅពេលក្រោយ។

អរគុណដល់អ្នកចូលរួមដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លឹប ពេលក្រោយ ឧទាហរណ៍ដូចជា "អ្នកទាំងអស់គ្នាសូមប្រាប់ខ្ញុំបានទេថាតើពេលណាយើងជួបគ្នា ម្តងទៀត?" ថ្ងៃអង្គារ ម៉ោង៣ រសៀល។ យើងនឹងមកទាំងអស់គ្នាបានទេ? បាទ! ប្រាប់ថា អ្នកដែល បានមកថ្ងៃនេះទទួលបានផ្កាយមួយ។

# IS ១: សំណួរសាកល្បងក្នុងវគ្គបណ្តុះបណ្តាល
☐ មុនវគ្គ ☐ ក្រោយវគ្គ

១

ឈ្មោះ ៖ ..........................................................................................
កាលបរិច្ឆេទ៖ ....................................................................................
ទីតាំងក្លឹប ៖ .......................................................................................

1. តើការជួញដូរមនុស្ស មានអត្ថន័យយ៉ាងដូចម្តេច?
   a. ការនាំនរណាម្នាក់ឆ្លងដែនទៅកាន់ប្រទេសដទៃ
   b. ការប្រើល្បិច ឬបង្ខំមនុស្សឲ្យធ្លាក់ចូលទៅក្នុងការកេងប្រវ័ញ្ចកំលាំងពលកម្មការងារ
   c. លក់សត្វដែលកាចសាហាវ ដើម្បីបានអត្ថប្រយោជន៍
   d. លក់អាវុធ និងថ្នាំញៀនខុសច្បាប់

2. តើអំពើជួញដូរមនុស្ស និងអំពើរត់ពន្ធមនុស្សខុសគ្នាយ៉ាងដូចម្តេច?
   a. ការរត់ពន្ធ គឺគេជួលនរណាម្នាក់ឲ្យនាំឆ្លងដែនខុសច្បាប់ ប៉ុន្តែមានជម្រើសក្នុងការសម្រេចចិត្តធ្វើការងារ
   b. សំដៅលើជនដែលត្រូវបានគេជួញដូរ ហើយគ្មានជម្រើសថា តើពួកគេធ្វើអ្វីនៅពេលដែលពួកគេទៅដល់ទីកន្លែង
   c. ការរត់ពន្ធមនុស្សសំដៅលើការនាំឆ្លងដែនទៅក្រៅប្រទេស ឯការជួញដូរមនុស្សសំដៅលើការចរាចរក្នុងប្រទេស
   d. ជម្រើស "a" និង "b" ខាងលើ

3. តើការជួញដូរមនុស្ស អាចកើតមានឡើងនៅទីណាខ្លះ?
   a. កើតមានឡើងតែនៅកន្លែងដែលអ្នករស់នៅតែប៉ុណ្ណោះ
   b. កើតមានឡើងតែនៅកន្លែងទីប្រជុំជនជិតព្រំដែនតែប៉ុណ្ណោះ
   c. កើតមានឡើងនៅទីក្រុងធំៗតែប៉ុណ្ណោះ
   d. កើតមានឡើងនៅគ្រប់កន្លែងទាំងអស់ហ្នឹង

4. តើឈ្មួញជួញដូរមនុស្សប្រើល្បិចអ្វីខ្លះ ដើម្បីជួញដូរមនុស្ស ?
   a. ដើរតួជាភ្នាក់ងារជ្រើសរើសពលកម្មស្របច្បាប់
   b. សន្យាផ្តល់ និងជួយរកការងារទទួលបានប្រាក់ខែខ្ពស់
   c. ជនដែលប្រមូលយកឯកសារស្របច្បាប់របស់ពលករក្សាទុក( លិខិតឆ្លងដែន )
   d. ទាំងអស់ខាងលើ

5. ជំនាញក្នុងការនិយាយមានអត្ថន័យយ៉ាងដូចម្តេច?
   a. និយាយបានទាំងអស់ និងគ្រប់ពេលដែលអ្នកចង់
   b. និយាយថា "បាទ" ទៅកាន់អ្នករាល់គ្នា បើទោះបីជាមិនចង់ធ្វើក៏ដោយ
   c. និយាយពាក្យដែលមានអំណះអំណាងច្បាស់លាស់ ហើយសមរម្យ
   d. គ្មានចម្លើយដូចខាងលើ

6. សូមមេត្តាជួយពិពណ៌នាពីជំនាញក្នុងការស្តាប់ មានអត្ថន័យយ៉ាងដូចម្តេច?
   a. កំពុងតែនិយាយជាមួយអ្នក ប៉ុន្តែគិតរឿងផ្សេង
   b. មិនយល់ទាល់តែសោះ ប៉ុន្តែធ្វើជាយល់ច្បាស់
   c. ស្តាប់យ៉ាងយកចិត្តទុកដាក់បំផុត ហើយសំយោគនៅអ្វីដែលគេបាននិយាយ ដើម្បីបានយល់កាន់តែច្បាស់ថែមទៀត
   d. មិនសួរសំណួរអ្វីទាំងអស់ ទោះបីជាចង់ដឹងរឿងបន្ថែមក៏ដោយ

7. សូមអ្នកជ្រើសរើសចំលើយពីរបៀបនៃការពិចារណា មុនពេលធ្វើការសម្រេចចិត្ត?
   a. ធ្វើតាមគំនិតរបស់មិត្ត គឺល្អណាស់
   b. ធ្វើតាមតែគំនិតរបស់ឪពុកម្តាយ គឺល្អណាស់
   c. ស្វែងរកព័ត៌មានឲ្យបានច្រើន ហើយប្រឹក្សាជាមួយបុគ្គលដែលអ្នកទុកចិត្ត មុនពេលធ្វើការសម្រេចចិត្ត
   d. គ្មានចម្លើយដូចខាងលើ

8. សូមជួយពិពណ៌នាថា តើ ថ្នាំញៀន អាចប៉ះពាល់អ្វីខ្លះដល់មនុស្ស?
   a. ឆ្លងជម្ងឺ អេដស៍ និងជម្ងឺផ្សេងៗទៀត នៅពេលចាក់ថ្នាំញៀន ដោយប្រើម្ជុលរួមគ្នា
   b. សេពគ្រឿងញៀន ធ្វើឲ្យអ្នកស្ថិតក្នុងភាពប្រឈមមុខនឹងគ្រោះថ្នាក់
   c. សេពគ្រឿងញៀន ជួយឲ្យការចងចាំបានល្អ
   d. ជម្រើស "a" និង "b" ខាងលើ

9. តើសកម្មភាពអ្វីខ្លះ ដែលអាចជួយអ្នកមានសុវត្ថិភាពពេលអ្នកទៅធ្វើការនៅប្រទេសដទៃ?
   a. ដាក់លិខិតឆ្លងដែន និងទិដ្ឋាការធ្វើការជាប់ខ្លួន នៅពេលទៅធ្វើការក្នុងប្រទេសដទៃ
   b. យកឯកសារសំខាន់នានារបស់អ្នកតាមខ្លួន នៅពេលអ្នកត្រលប់មកផ្ទះវិញ
   c. យកថវិការឲ្យបានគ្រប់គ្រាន់សម្រាប់ទូទាត់សោហ៊ុយធ្វើដំណើរនៅពេលត្រឡប់មកផ្ទះ
   d. ចម្លើយទាំងអស់ខាងលើ

10. នៅក្នុងប្រទេសរបស់អ្នក តើប្រព័ន្ធទូរស័ព្ទមួយណា ដែលអ្នកត្រូវទំនាក់ទំនងជាបន្ទាន់នៅពេលមានគ្រោះថ្នាក់ ឬមានការជួញដូរមនុស្សកើតឡើង?
    a. (844) 3936 6633
    b. 1300

c. (856) 20 5483 8969
d. (95) 67 412 555
e. (855) 017 276 222
f. 12333

11. នៅក្នុងប្រទេសទទួល/ប្រទេសគោលដៅ តើប្រព័ន្ធទូរស័ព្ទមួយណា ដែលអ្នកត្រូវទំនាក់ទំនងជាបន្ទាន់ នៅពេលមានគ្រោះថ្នាក់ ឬមានការជួយដូរមនុស្សកើតឡើង?
a. (844) 3936 6633
b. 1300
c. (856) 20 5483 8969
d. (95) 67 412 555
e. (855) 017 276 222
f. 12333

12. តើលិខិតឆ្លងដែនជាអ្វី?
a. ជាលិខិតអនុញ្ញាតិឲ្យចេញ និងចូលប្រទេសរបស់ខ្លួន ដែលចេញដោយរដ្ឋាភិបាលនៃប្រទេសរបស់អ្នក
b. ជាសន្លឹកក្រដាសពិសេសមួយ ដែលអនុញ្ញាតិឲ្យអ្នកធ្វើដំណើរទៅកាន់ខេត្តផ្សេងៗបាន
c. ជាឯកសារចុះហត្ថលេខា ដោយមេភូមិក្នុងភូមិរបស់អ្នក
d. គ្មានចម្លើយដូចខាងលើ

13. តើទិដ្ឋាការជាអ្វី?
a. ជាសំបុត្រសម្រាប់ទិញម្ហូបអាហារ
b. ជាត្រា ឬក៏តែមបិតលើលិខិតឆ្លងដែនអាចឲ្យអ្នកឆ្លងទៅប្រទេសផ្សេងបានដោយស្របច្បាប់
c. ស្នាមត្រាក្នុងសំបុត្រកំណើតរបស់អ្នក
d. គ្មានចម្លើយដូចខាងលើ

14. តើទិដ្ឋាការធ្វើការ និងទិដ្ឋាការធ្វើដំណើរកំសាន្ត ខុសគ្នាយ៉ាងដូចម្តេច?
a. ទិដ្ឋាការធ្វើការ អ្នកអាចធ្វើការនៅប្រទេសដទៃបានដោយស្របច្បាប់ ឯទិដ្ឋាការធ្វើដំណើរកំសាន្តអនុញ្ញាតិបានតែដំណើរកំសាន្តប៉ុណ្ណោះ មិនអាចធ្វើការបានទេ
b. ទិដ្ឋាការធ្វើការអនុញ្ញាតិឲ្យអ្នកធ្វើការនៅឯផ្ទះ ឯទិដ្ឋាការធ្វើដំណើរកំសាន្តអនុញ្ញាតិឲ្យ អ្នកធ្វើដំណើរទៅកាន់ខេត្តផ្សេងៗទៀតដើម្បីកំសាន្តសប្បាយ
c. ទិដ្ឋាការធ្វើការអនុញ្ញាតិឲ្យអ្នកធ្វើដំណើរទៅកាន់ប្រទេសមួយទៀត ដើម្បីកំសាន្តសប្បាយ ឯទិដ្ឋាការធ្វើដំណើរកំសាន្តអនុញ្ញាតិឲ្យអ្នកធ្វើដំណើរកំសាន្តមានរយៈពេលយូរ
d. គ្មានចម្លើយខាងលើ

15.ប្រសិនបើអ្នកមានបំណងធ្វើចំណាក់ស្រុក ជំហានអ្វីខ្លះដែលជួយអោយអ្នកចំណាកស្រុកប្រកដដោយសុវត្ថិភាព?

a. ទៅដោយមិនចាំបាច់សួរនរណាទាំងអស់

b. ប្រាប់ភ្លាមទៅភ្លាម

c. ទៅតាមមិត្តភក្តិប្រាប់ដោយមិនបានពិភាក្សាជាមួយឪពុកម្តាយ

d. ស្វែងរកព័ត៌មានអោយបានច្រើន ស្តីពីទីកន្លែង ការធ្វើដំណើរ និងប្រភេទនៃការងារមុនពេលធ្វើចំណាកស្រុក

16.តើអ្នកធ្លាប់រៀបចំអ្វីខ្លះ ដើម្បីជួយដល់យុវជនក្នុងសហគមន៍របស់អ្នកដែរ ឬទេ? ប្រសិនបើបាទ សូមជួយរៀបរាប់?

□បាទ/ចាស់□ទេ

# មេរៀនទី ២ ៖ ការគិតអំពីជីវិតរបស់យើង ២

**ឧទ្ទេសបំណង**
ដើម្បីជួយឲ្យអ្នកចូលរួមឲ្យដឹងពីខ្លួនឯងកាន់តែច្បាស់ និងដើម្បីឈានជំហានទីមួយក្នុងការគិតគូរពីអនាគតរបស់ខ្លួន។

**ពេលវេលា**
៧៥ នាទី

**ការត្រៀម**
ព្យួរក្រដាសវិន័យ
កាលពីសប្តាហ៍មុន

**សម្ភារៈ**

- ក្រដាសវែងមួយសម្រាប់អ្នកចូលរួមម្នាក់ៗ (អ្នកប្រើក្រដាសធម្មតា បិសន្លឹកតគ្នាដើម្បីធ្វើជាក្រដាសវែងមួយ)
- សៀវភៅកំណត់ហេតុសម្រាប់អ្នកចូលរួមម្នាក់ៗ (សៀវភៅកំណត់ហេតុគួរជាសៀវភៅមានក្រឡាធម្មតាមានច្រើនទំព័រ)
- ប្រអប់ចាក់សោជិតមួយដើម្បីដាក់សៀវភៅកំណត់ហេតុ
- ប៊ិច ១០ ឈុត

**សេចក្តីផ្តើម**

**ការស្វាគមន៍**
ស្វាគមន៍អ្នកចូលរួមដោយហៅឈ្មោះ។
ហុចតគ្នានូវបញ្ជីវត្តមាន។

**សកម្មភាពមុនចាប់ផ្តើម**
សុំឲ្យអ្នកសម្របសម្រួលជាយុវជនដឹកនាំ
ល្បែងថាមពលនៅក្នុងតារាង។

**ការរំឭកមេរៀន**
តើអ្នកបានចាំខ្លះទេអំពីវិន័យកាលពីសប្តាហ៍មុន?
តើអ្នកអាចរៀបរាប់បានដែរ ឬទេថា តើប្រព័ន្ធផ្កាយដំណើរការដូចម្តេច?

## ទន្លេនៃខ្សែជីវិត

ប្រគល់ក្រដាសវែង និងប៊ិចពណ៌។ ពន្យល់ថា គំនូរនេះគឺគេហៅថា ទន្លេនៃខ្សែជីវិត ហើយវានឹងរៀបរាប់នូវរឿងរ៉ាវក្នុងជីវិតរបស់គេ។ សកម្មភាពនេះជួយឲ្យអ្នកចូលរួមដឹងកាន់តែច្រើន អំពីជីវិត និងអ្វីដែលគេចង់បាននៅក្នុងជីវិតរបស់គេ។ ពន្យល់ប្រាប់ថា មិនមាន បញ្ហា អ្វីនោះទេ ប្រសិនទរណាមិនពូកែគូរគំនូរនោះ ពីព្រោះវាផ្តោតសំខាន់តែលើការសម្តែងនូវគំនិតរបស់ពួកគេ និងប្រាប់ពីរឿងរ៉ាវរបស់គេតែប៉ុណ្ណោះ។

ពន្យល់ថានៅពេលចាប់ផ្តើមពួកគេគួរបង្កើតរូបភាពមួយរបស់ខ្លួនជាកុមារម្នាក់ដែលអាចរួមមាន៖

- គ្រួសាររបស់គេ
- ភូមិរបស់គេ

- អ្វីដែលគេចូលចិត្តធ្វើពេលនៅក្មេង
- ព្រឹត្តិការណ៍នៅក្នុងកុមារភាពរបស់គេ ល្អ ឬអាក្រក់ ដែលគេគិតថាសំខាន់។

បន្ទាប់មកប្រាប់អ្នកចូលរួម ឲ្យបង្កើតរូបភាពមួយអំពីខ្លួនគេ នៅចំកណ្ដាលនៃក្រដាស់ អំពីបច្ចុប្បន្នកាល។ គេអាចរួមបញ្ចូល ៖

- មិត្តភក្តិរបស់គេ
- អ្វីដែលគេចូលចិត្តធ្វើ
- អ្វីដែលគេគិតថា គេពូកែធ្វើ
- អ្វីដែលគេចង់ផ្លាស់ប្ដូរចំពោះជីវិតរបស់គេ
- ទិដ្ឋភាពណាមួយនៃជីវិតរបស់គេ ល្អ ឬអាក្រក់ ដែលជះឥទ្ធិពលលើរូបគេ។

ជាចុងក្រោយ ប្រាប់អ្នកចូលរួមថា នៅផ្នែកខាងចុងនៃក្រដាសវែងនេះ គេអាចគូររូបអនាគតរបស់គេដែលគេចង់បាន ៖

- ទំនាក់ទំនងរបស់គេ
- ការងាររបស់គេ
- អ្វីដែលគេធ្វើដើម្បីកំសាន្តសប្បាយ។

ប្រាប់អ្នកចូលរួម ឲ្យសរសេរខាងក្រោមរូបភាពបន្តិច អំពីជំហានដែលគេនឹងឈាន ដើម្បីទៅដល់អនាគតដែលគេចង់បាន។

សួរពួកគេថា តើមាននរណាម្នាក់ចង់ចែករំលែកលំហូរនៃខ្សែជីវិតរបស់គេដែរ ឬទេ។ មិនត្រូវបង្ខំនរណាម្នាក់ឡើយ គឺទុកឲ្យគេស្ម័គ្រចិត្តដោយខ្លួនឯង (ឬ មិនបាច់ក៏បាន)។

## ការពិភាក្សា

បែងចែកអ្នកចូលរួមជាក្រុមតូចៗមានគ្នាពី ៦-៨ នាក់។ ឲ្យពួកគេអង្គុយរួមគ្នានៅក្នុងក្រុមតូចៗរបស់ខ្លួន។ ប្រសិនបើ SNYC មានអ្នកសម្របសម្រួលជាយុវជន សុំឲ្យគេសម្របសម្រួលការពិភាក្សានេះ។ សុំឲ្យក្រុមទាំងអស់ពិចារណាលើសំណួរខាងក្រោមទាំងអស់គ្នា។ រំឭកដល់ក្រុមថាអ្នកគ្រប់គ្នាគួរមានឱកាសក្នុងការនិយាយ ហើយគ្មានចម្លើយណាដែល "ត្រូវ"រឺ"ខុស" នោះទេ។

- តើអ្នកគិតថា មនុស្សភាគច្រើនមានគោលដៅសម្រាប់ជីវិតរបស់គេមែន ឬទេ ឬមនុស្សភាគច្រើនបណ្ដែតបណ្ដោយជីវិតរបស់ខ្លួនដូចជា ស្លឹកឈើដែលអណ្ដែតតាមដងទន្លេ ដោយគ្មានផែនការអ្វីសោះ?
- តើហេតុអ្វីបានជាពេលខ្លះមនុស្សសម្រេចគោលដៅរបស់ខ្លួនបាន ហើយពេលខ្លះមិនអាចសម្រេចបាន?
- តើអ្នកនឹងធ្វើអ្វី ប្រសិនបើជួបប្រទះបញ្ហាក្នុងការសម្រេចឲ្យបានគោលដៅរបស់អ្នក?

## ណែនាំអំពីសៀវភៅកំណត់ហេតុ

ផ្ដល់ឲ្យអ្នកចូលរួមម្នាក់ៗនូវសៀវភៅកំណត់ហេតុមួយ និងប៊ិចមួយ។

ពន្យល់ប្រាប់ថា សៀវភៅកំណត់ហេតុគឺជាសៀវភៅមួយក្បាលដែលគេអាចសរសេរអំពីគំនិត និងអារម្មណ៍របស់គេបាន។ វាជាការសម្ងាត់។ មិនមាននរណាម្នាក់អាចអានបានទេ។ សូម្បីតែ

អ្នកសម្របសម្រួលនឹងមិនអានផងដែរ។ វានឹងត្រូវបានរក្សាទុកនៅក្នុងប្រអប់ចាក់សោរជិតនៅ SNYC។

ពន្យល់ថា សៀវភៅកំណត់ហេតុគឺជាសៀវភៅស្តីពីជីវិតរបស់គេ។ គេនឹងត្រូវសរសេរចូលក្នុងសៀវភៅកំណត់ហេតុនូវអ្វីដែលបានកើតឡើងចំពោះរូបគេ អ្វីដែលគេមានអារម្មណ៍ ឬអ្វីដែលត្រូវបានពិភាក្សានៅក្នុង SNYC ។ គេអាចសរសេរពីអ្វីគ្រប់យ៉ាងបានទាំងអស់។

ប្រាប់អ្នកចូលរួមថា ប្រសិនបើគេចង់ គឺគេអាចគូររូបភាពអំពីជីវិតរបស់គេបាននៅក្នុងសៀវភៅកំណត់ ហេតុរបស់ខ្លួន។

ពន្យល់ថា ពេលខ្លះអំឡុងពេលនៅ SNYC អ្នកសម្របសម្រួលនឹងសុំឲ្យអ្នកចូលរួមសរសេរអំពីប្រធានបទ ជាក់លាក់មួយពីក្នុង ឧបករណ៍ទៅក្នុងសៀវភៅកំណត់ហេតុរបស់គេ ប៉ុន្តែគេមិនចាំបាច់ ត្រូវតែចែករំលែកអ្វីដែលគេបានសរសេរនៅក្នុងក្រុមរបស់គេនោះទេ។ វានៅតែជាការសម្ងាត់។

សុំឲ្យក្រុមសរសេរចូលទៅក្នុងសៀវភៅកំណត់ហេតុរបស់គេនូវចុងមេរៀន ដោយរៀបរាប់ អំពីជីវិត គោលដៅ និងបញ្ហាប្រឈមរបស់គេ។

នៅចុងបញ្ចប់នៃមេរៀន ត្រូវប្រមូលសៀវភៅកំណត់ហេតុទុកក្នុងប្រអប់មានចាក់សោរជិតរហូតទាល់តែដល់មេរៀនបន្ទាប់ទៀត។

**សេចក្តីសង្ខេបមេរៀន**

- វាអាចជាការល្អក្នុងការដែលត្រូវដឹងពីខ្លួនឯង និងឆ្លុះបញ្ចាំងពីជីវិតរបស់ខ្លួន។
- សៀវភៅកំណត់ហេតុអាចជួយធ្វើកិច្ចការនេះបាន។
- មានតែអ្នកចូលរួមប៉ុណ្ណោះដែលអាចអានសៀវភៅកំណត់ហេតុរបស់ខ្លួនបាន។

## ការបិតបញ្ចប់

សុំឲ្យអ្នកចូលរួមសរសេរ ឬសួរសំណួរ និង/ឬផ្តល់ព័ត៌មានត្រឡប់ ហើយប្រគល់វាឲ្យទៅអ្នកសម្របសម្រួលដោយសម្ងាត់។

អរគុណដល់ពួកគេដែលបានមកចូលរួម។ បញ្ជាក់ឡើងវិញអំពីការប្រជុំក្លិបពេលក្រោយ។ ប្រាប់ពួក គេថាប្រសិនបើគេបានចូលរួមទាំងពីរមេរៀននោះ ពេលនេះគេទទួល បានផ្កាយមួយទៀត។

សុំឲ្យអ្នកចូលរួមពិចារណាអំពីប្រជាជននៅក្នុងសហគមន៍របស់គេ និងឆ្លើយសំណួរខាងក្រោម ៖

- តើអ្នកគិតថា ប្រជាជននៅក្នុងសហគមន៍អ្នកមានគោលដៅដែរ ឬទេ?
- តើគោលដៅរបស់ពួកគាត់មានអ្វីខ្លះ?

អ្នកសម្របសម្រួល អាចឲ្យអ្នកចូលរួម កត់សំណួរទាំងនេះលើក្រដាសសំណួរដើម្បីយកទៅផ្ទះកុំឲ្យភ្លេច។